## សេចក្តីផ្តើមស្តីពីយន្តការអភិវឌ្ឍន៍ស្អាត

# យន្តការ
# អភិវឌ្ឍន៍
# ស្អាត

ទំព័រ

យន្តការអភិវឌ្ឍន៍ស្អាត------------------------------------------------------------------- 3
សេចក្តីសង្ខេបស្តីពីយន្តការអភិវឌ្ឍន៍ស្អាត---------------------------------------------- 10
តំលៃ និងអត្ថប្រយោជន៍ជាតិ ------------------------------------------------------- 18
ការកសាងយុទ្ធសាស្ត្រនៃយន្តការអភិវឌ្ឍន៍ស្អាតថ្នាក់ជាតិ ----------------------------- 21
សេចក្តីបញ្ចប់--------------------------------------------------------------------------- 26
ឧទាហរណ៍នៃគំរោងយន្តការអភិវឌ្ឍន៍ស្អាត ------------------------------------------- 27

UNEP

# យន្តការអភិវឌ្ឍន៍ស្អាត
The Clean Development Mechanism (CDM)

មជ្ឈមណ្ឌលសហប្រតិបត្តិការផ្នែកថាមពល
និងបរិស្ថាននៃកម្មវិធីបរិស្ថានសហប្រជាជាតិ
មន្ទីរពិសោធន៍ជាតិ Risø
ទីក្រុង Roskilde ប្រទេសដាណឺម៉ាក

ISBN: 87-550-386-6

រចនាក្រាភិចដោយ :
Finn Hagen Madsen, Graphic Design, Denmark
បកប្រែជាភាសាខ្មែរដោយលោក **ស៊ុំ ធី**
ពិនិត្យផ្ទៀងផ្ទាត់ និងកែសំរួលដោយលោក **ឆិន ពន្លក**

លទ្ធផល ការបកស្រាយ និងសេចក្ដីសន្និដ្ឋាន ដែលមានចែងនៅក្នុងសៀវភៅនេះ គឺជារបស់អ្នកនិពន្ធទាំងស្រុង ហើយពុំតំណាងឱ្យមតិយោបល់ណាមួយរបស់រដ្ឋាភិបាលហុល្លង់ឡើយ ។

## យន្តការអភិវឌ្ឍន៍ស្អាត
**(The Clean Development Mechanism: CDM)**

### សេចក្តីផ្តើម

យន្តការអភិវឌ្ឍន៍ស្អាតជាយន្តការរួមគ្នា ដែលបានបង្កើតឡើងនៅក្រោមពិធីសារក្យូតូ មានសក្តានុពលខ្ពស់ក្នុងការជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីឈានទៅសំរេចការអភិវឌ្ឍន៍ដោយចីរភាព តាមរយៈការលើកកំពស់ការវិនិយោគ ដែលគិតគូរដល់បរិស្ថាន ពីរដ្ឋាភិបាល និងអ្នកជំនួញនៃបណ្តាប្រទេសឧស្សាហកម្ម * ។ ឯកសារនេះផ្តល់នូវសេចក្តីសង្ខេបស្តីពីប្រវត្តិដើមរបស់យន្តការអភិវឌ្ឍន៍ស្អាត រចនាសម្ព័ន្ធគំរោង និងវដ្តគំរោង ព្រមទាំងពិនិត្យមើលតំលៃជាតិ និងអត្ថប្រយោជន៍ជាសក្តានុពល សំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលចូលរួមក្នុងពិធីសារ ។ ឯកសារនេះក៏ណែនាំជាជំហាន១ផងដែរ ស្តីពីការរៀបចំយុទ្ធសាស្ត្រ CDM ជាតិ និងផ្តល់ជូននូវឧទាហរណ៍ផ្សេង១ ស្តីពីគំរោង CDM ។ ពិតមែនតែវិធានច្បាប់ជាមូលដ្ឋានត្រូវបានបង្កើតហើយក្តី ក៏ CDM គឺជាការងារមួយដែលវិវត្ត ដោយមានការចូលរួមពីបណ្តារដ្ឋាភិបាលនានា ។ ឯកសារនេះបង្ហាញពីពតិមានចុងក្រោយបំផុតដែលមាន ហើយនឹងត្រូវកែសំរួលជាថ្មីនៅពេលអនាគត ដើម្បីឆ្លុះបញ្ចាំងនូវការផ្លាស់ប្តូរសំខាន់១ ។

### ប្រវត្តិដើម

ពិធីសារក្យូតូឆ្នាំ 1997 ដែលជាព្រឹត្តិការណ៍ដ៏សំខាន់ក្នុងការខិតខំប្រឹងប្រែងជាសកល ដើម្បីការពារបរិស្ថាន និងសម្រេចនូវការអភិវឌ្ឍន៍ដោយចីរភាព បានកំណត់ជាលើកទីមួយថា បណ្តារដ្ឋាភិបាលនានាត្រូវទទួលយកការសន្យាជាលក្ខណៈច្បាប់ ក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់របស់ខ្លួន ។ ពិធីសារនេះក៏បានបង្កើតឡើងនូវ " យន្តការរួម " ថ្មី១ សំដៅ

---

* ពិធីសារក្យូតូក៏ផ្តល់នូវលទ្ធភាពសំរាប់គំរោង CDM ជាឯកតោភាគីដែរ ពោលគឺវិនិយោគិនអាចមានប្រភពមកពីប្រទេសកំពុងអភិវឌ្ឍន៍ ។

កាត់បន្ថយតំលៃនៃការទប់ស្កាត់ការបញ្ចេញឧស្ម័នទាំងនោះ ។ ដោយសារការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ពុំអាស្រ័យទៅនឹងទីកន្លែងដែលឧស្ម័នត្រូវកាត់បន្ថយ នោះតាមលក្ខណៈសេដ្ឋកិច្ច គេត្រូវអនុវត្តការកាត់បន្ថយឧស្ម័ននៅទីណាដែលចំណាយតិច ។ ដូច្នេះពិធីសារក៏បញ្ចូលយន្តការផ្អែកលើទីផ្សារចំនួនបី គឺ : ការធ្វើពាណិជ្ជកម្មអន្តរជាតិលើការបញ្ចេញឧស្ម័ន (International Emission Trading) ការអនុវត្តន៍រួមគ្នា (Joint Implementation) និងយន្តការអភិវឌ្ឍន៍ស្អាត (CDM) ក្នុងគោលបំណងសំរេចឱ្យបាននូវការកាត់បន្ថយឧស្ម័នប្រកបទៅដោយប្រសិទ្ធិភាពសេដ្ឋកិច្ច ។ យន្តការអភិវឌ្ឍន៍ស្អាត ដែលមានចែងនៅក្នុងមាត្រាទី 12 នៃពិធីសារក្យូតូ អនុញ្ញាតឱ្យរដ្ឋាភិបាល ឬក្រុមហ៊ុនឯកជន នៅក្នុងបណ្តាប្រទេសឧស្សាហកម្ម អនុវត្តគំរោងកាត់បន្ថយឧស្ម័ននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ហើយទទួលបានឥណទានក្នុងទំរង់ជា "ការកាត់បន្ថយឧស្ម័នដែលបានបញ្ជាក់ " (Certified Emission Reduction: CERs) ដែលអាចគិតបញ្ចូល ទៅក្នុងទិសដៅនៃការកាត់បន្ថយឧស្ម័នថ្នាក់ជាតិរបស់គេ ។ យន្តការអភិវឌ្ឍន៍ស្អាតខិតខំជំរុញការអភិវឌ្ឍន៍ដោយចីរភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដោយអនុញ្ញាតឱ្យប្រទេសអភិវឌ្ឍន៍រួមចំណែកដល់ទិសដៅកាត់បន្ថយកំហាប់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាស ។

| |
|---|
| មាត្រាទី 12.2 នៃពិធីសារក្យូតូ :" គោលបំណងនៃយន្តការអភិវឌ្ឍន៍ស្អាត គឺដើម្បីជួយដល់ភាគីដែលមិននៅក្នុងឧបសម្ព័ន្ធទី 1 ឱ្យសំរេចនូវការអភិវឌ្ឍន៍ដោយចីរភាព និងរួមចំណែកដើម្បីសំរេចទិសដៅចុងក្រោយរបស់អនុសញ្ញា ព្រមទាំងជួយដល់ភាគីក្នុងឧបសម្ព័ន្ធទី 1 ក្នុងការសំរេចការសន្យាកំហិត និងកាត់បន្ថយបរិមាណបញ្ចេញឧស្ម័ន នៅក្រោមមាត្រាទី 3 " ។ |

## អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងពិធីសារក្យូតូ

ភស្តុតាងវិទ្យាសាស្ត្រ ស្តីពីឥទ្ធិពលរបស់មនុស្សទៅលើប្រព័ន្ធអាកាសធាតុ ព្រមទាំងកំណើនកង្វល់សាធារណៈជនអំពីបញ្ហាបរិស្ថាន បានជំរុញប្រធានបទស្តីពីការប្រែប្រួល

អាកាសធាតុ ទៅក្នុងរបៀបវារៈនយោបាយ នៅពាក់កណ្តាលទសវត្សឆ្នាំទី ៨០ ។ នៅឆ្នាំ 1988 កម្មវិធីបរិស្ថានសហប្រជាជាតិ (United Nations Environmental Program: UNEP) និងអង្គការឧតុនិយមពិភពលោក (World Meteorology Organization: WMO) បានបង្កើតក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (Intergovernmental Panel on Climate Change: IPCC) សំរាប់ផ្តល់ជូនអ្នកនយោបាយនូវពត៌មានវិទ្យាសាស្ត្រ ដែលអាចយកជាការបាន ។ ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ ដែលរួមមានអ្នកវិទ្យាសាស្ត្រ និងអ្នកជំនាញការផ្នែកកំណើនកំដៅពិភពលោកល្បី១រាប់រយនាក់ ត្រូវបានគេប្រគល់ភារកិច្ចឱ្យធ្វើការវាយតំលៃអំពីស្ថានភាពចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុ វាយតំលៃទៅលើសក្តានុពលនៃផលប៉ះពាល់បរិស្ថាន និងសេដ្ឋកិច្ចសង្គម ព្រមទាំងផ្តល់យោបល់ផ្នែកគោលនយោបាយ ប្រកបដោយភាពប្រាកដនិយម ។

ពីរឆ្នាំក្រោយមក គឺនៅឆ្នាំ 1990 ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ បានបោះពុម្ពផ្សាយរបាយការណ៍មួយ ដោយសន្និដ្ឋានថា : កំនើននៃកំហាប់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាស ដែលបង្កឡើងដោយសកម្មភាពមនុស្ស នឹងបង្កើន " ផលផ្ទះកញ្ចក់ ដែលបណ្តាលឱ្យមានកំណើនកំដៅបន្ថែមដល់ផ្ទៃផែនដី " នៅសតវត្សក្រោយនេះ ប្រសិនបើពុំមានវិធានការទប់ស្កាត់ការបញ្ចេញឧស្ម័ននេះទេនោះ ។ របាយការណ៍បានបញ្ជាក់ថែមទៀតថា ការប្រែប្រួលអាកាសធាតុគឺជាការគំរាមកំហែងមួយ ហើយបានអំពាវនាវឱ្យបង្កើតនូវសន្ធិសញ្ញាអន្តរជាតិមួយ ដើម្បីដោះស្រាយបញ្ហានេះ ។ ក្រោយមក នៅឆ្នាំដដែល មហាសន្និបាតពិភពលោកលើកទី 2 ស្តីពីអាកាសធាតុ បានចេញនូវសេចក្តីអំពាវនាវដូចគ្នានេះដែរ ។ មហាសន្និបាតអង្គការសហប្រជាជាតិបានឆ្លើយតប ដោយចាប់ផ្តើមកិច្ចចរចាជាផ្លូវការស្តីពី អនុសញ្ញាក្របខ័ណ្ឌស្តីពីការប្រែប្រួលអាកាសធាតុមួយ ហើយបានបង្កើតនូវ " គណៈ-កម្មាធិការចរចាអន្តររដ្ឋាភិបាល " (Intergovernmental Negotiating Committee) មួយឡើង ដើម្បីរៀបចំនូវអនុសញ្ញានេះ ។ កិច្ចចរចាដើម្បីបង្កើតអនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារអាកាសធាតុពិភពលោក បានចាប់ផ្តើមនៅឆ្នាំ 1991 ហើយជាលទ្ធផលបានបង្កើតនូវ

អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (the United Nations Framework Convention on Climate Change: UNFCCC) នៅខែ ឧសភា ឆ្នាំ 1992 ។

## អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (United Nations Framework Convention on Climate Change: UNFCCC)

អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ត្រូវបានបើកឱ្យចុះហត្ថលេខានៅឯសន្និសីទសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍ (កិច្ចប្រជុំកំពូលពិភពលោក) នៅទីក្រុងរីយូដឺសានេរ៉ូ ប្រទេសប្រេស៊ីល នាខែមិថុនា ឆ្នាំ 1992 ហើយបានចូលជាធរមាន នៅខែមីនា ឆ្នាំ 1994 ។ អនុសញ្ញានេះបានដាក់ចុះនូវ "ទិសដៅចុងក្រោយមួយ" ស្តីពីការធ្វើឱ្យមានភាពលំនឹងកំហាប់ឧស្ម័នផ្ទះកញ្ចក់ក្នុងបរិយាកាស ក្នុងកំរិតមួយមានសុវត្ថិភាព ។ អនុសញ្ញាពុំបានបញ្ជាក់កំរិតនេះជាបរិមាណទេ តែបានបញ្ជាក់ថា គួរត្រូវបានសំរេចឡើង ក្នុងអំឡុងពេលមួយគ្រប់គ្រាន់ ដែលអាចឱ្យប្រព័ន្ធអេកូឡូស៊ីផ្សាំទៅនឹងការប្រែប្រួលអាកាសធាតុតាមធម្មជាតិ ដើម្បីធានាឱ្យបានថា គ្មានការគំរាមកំហែងដល់ផលិតកម្មស្បៀង និងជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចតាមបៀបមួយដែលមានចីរភាព ។ ដើម្បីសំរេចទិសដៅនេះ ប្រទេសទាំងអស់មានកាតព្វកិច្ចទូទៅមួយ សំដៅដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ការបន្សាំទៅនឹងឥទ្ធិពលរបស់វា និងធ្វើរបាយការណ៍សកម្មភាពរបស់ខ្លួនស្តីពីការអនុវត្តអនុសញ្ញា ។ មកទល់ខែធ្នូ ឆ្នាំ 2001 អនុសញ្ញាបានទទួលលិខិតូបករណ៍ផ្តល់សច្ចាប័នចំនួន 186 ។

អនុសញ្ញានេះចែកប្រទេសជាពីរក្រុម គឺ : ភាគីនៅក្នុងឧបសម្ព័ន្ធទី 1 (Annex I Parties) ជាប្រទេសឧស្សាហកម្ម ដែលមានប្រវត្តិរួមចំណែកច្រើនជាងគេបំផុតដល់ការប្រែប្រួលអាកាសធាតុ និងភាគីមិននៅក្នុងឧបសម្ព័ន្ធទី 1 (non-Annex I Parties) ដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ។ គោលការណ៍សមធម៌ និង " ការទទួលខុសត្រូវរួមគ្នា តែមានកំរិតផ្សេងៗគ្នា " ដែលមានចែងនៅក្នុងអនុសញ្ញា តំរូវឱ្យភាគីនៅក្នុងឧបសម្ព័ន្ធទី 1 ធ្វើជាគំរូក្នុង

ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់គេ ឱ្យចុះដល់កំរិតដែលបានបញ្ចេញនៅឆ្នាំ 1990 នៅត្រឹមឆ្នាំ 2000 ។ ប្រទេសទាំងនោះត្រូវដាក់របាយការណ៍ជូនឱ្យបានទៀងទាត់ ដែលគេហៅថា របាយការណ៍ជាតិ (National Communication) ដោយមានអធិប្បាយលំអិតអំពីកម្មវិធី និងនយោបាយរបស់ខ្លួន ក្នុងវិស័យការប្រែប្រួលអាកាសធាតុ ព្រមទាំងអំពីសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ប្រចាំឆ្នាំផងដែរ ។

## ពិធីសារក្យូតូ

ពិធីសារក្យូតូត្រូវបានគេអនុមត័នៅខែ ធ្នូ ឆ្នាំ 1997 ។ ពិធីសារនេះបង្កើតនូវកាតព្វកិច្ចផ្លូវច្បាប់ ចំពោះប្រទេសឧស្សាហកម្មចំនួន 38 ដែលក្នុងនោះរួមមានប្រទេសចំនួន 11 នៅអឺរ៉ុបកណ្តាល និងអឺរ៉ុបខាងកើត ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់គេ ឱ្យបានជាមធ្យម 5,2% នៃកំរិតដែលបានបញ្ចេញនៅឆ្នាំ 1990 ក្នុងអំឡុងពេលរវាងឆ្នាំ 2008-2012 ។ ទិសដៅកាត់បន្ថយនេះរួមមានឧស្ម័នផ្ទះកញ្ចក់សំខាន់ៗចំនួន 6 គឺ ឧស្ម័នកាបូនិច ($CO_2$) ឧស្ម័នមេតាន ($CH_4$) ឧស្ម័នឌីអាសូតមូណូអុកស៊ីត ($N_2O$) ឧស្ម័នអ៊ីដ្រូភ្លុយអរ៉ូកាបូន (HFCs) ឧស្ម័នពែភ្លុយអរ៉ូកាបូន (PFCs) និងឧស្ម័នស៊ុលភួអ៊ិចសាភ្លុយអ័រ ។ ពិធីសារក៏បានអនុញ្ញាតឱ្យប្រទេសទាំងនោះធ្វើសេចក្តីសំរេចជ្រើសរើសយកឧស្ម័នណា ក្នុងចំណោមឧស្ម័នទាំង 6 ដើម្បីបញ្ចូលទៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយឧស្ម័នថ្នាក់ជាតិរបស់ខ្លួន ។ ពិធីសារក៏បានបញ្ចូលផងដែរនូវសកម្មភាពមួយចំនួននៅក្នុងវិស័យការប្រើប្រាស់ដី និងព្រៃឈើ ដូចជាការកាប់ព្រៃ និងការដាំព្រៃឈើ ដែលបញ្ចេញ និងស្រូបឧស្ម័នកាបូនិចពីបរិយាកាស ។ កិច្ចចរចាបានធ្វើឡើងជាបន្តបន្ទាប់ ក្រោយពីសន្និសីទនៅទីក្រុងក្យូតូ ដើម្បីតាក់តែងបែបបទលំអិតសំរាប់ការអនុវត្តន៍ពិធីសារនេះ ។ ពិតមែនតែពិធីសារនេះកំណត់នូវវិធីមួយចំនួនសំរាប់ជួយបណ្តាភាគីជាសមាជិក ឱ្យសំរេចទិសដៅខ្លួនក្តី ក៏វាមិនបានអធិប្បាយឱ្យបានជាក់លាក់ពីចំនុចលំអិតឡើយ ។ បន្ទាប់ពីការជជែកពិភាក្សាអស់រយៈពេលជាង 4 ឆ្នាំមក ទីបញ្ចប់បណ្តារដ្ឋាភិបាលទាំងឡាយបានឯកភាព ទៅលើសៀវភៅវិធានដ៏ទូលំទូលាយមួយ ដែលហៅថាកិច្ចព្រមព្រៀងម៉ារ៉ាកេស (Marrakech Accords) ស្តីពីរបៀបអនុវត្ត

ពិធីសារក្យូតូ ។ កិច្ចព្រមព្រៀងនេះក៏មានគោលបំណងផ្តល់ជូនដល់រដ្ឋាភិបាលទាំងឡាយ នូវភាពច្បាស់លាស់គ្រប់គ្រាន់ សំរាប់ការពិចារណាផ្តល់សច្ចាបន័ដល់ពិធីសារ ។

**យន្តការអភិវឌ្ឍន៍ស្អាត និងយន្តការរួម (the Clean Development Mechanism (CDM) and the Cooperative Mechanisms)**

ពិធីសារបង្កើតយន្តការរួមគ្នាចំនួន 3 ដែលរៀបចំឡើង ដើម្បីជួយបណ្តាប្រទេសឧស្សាហកម្ម (ភាគីនៅក្នុងឧបសម្ព័ន្ធទី 1) ក្នុងការបន្ថយប្រាក់ចំណាយលើការកាត់បន្ថយការបញ្ចេញឧស្ម័នរបស់គេ តាមរយៈការកាត់បន្ថយការបញ្ចេញឧស្ម័នដែលចំណាយតិច នៅបណ្តាប្រទេសដ៏ទៃ ។

- *ការធ្វើពាណិជ្ជកម្មអន្តរជាតិលើការបញ្ចេញឧស្ម័ន (International Emission Trading)* អនុញ្ញាតឱ្យប្រទេសទាំងឡាយផ្ទេរផ្នែកណាមួយនៃការបញ្ចេញឧស្ម័នរបស់ខ្លួន ដែលបានអនុញ្ញាតឱ្យ (បរិមាណឯកតាដែលបានកំណត់) ។
- *ការអនុវត្តន៍រួមគ្នា (Joint Implementation: JI)* អនុញ្ញាតឱ្យប្រទេសទាំងឡាយទទួលយកឥណទានពីការកាត់បន្ថយឧស្ម័ន ដែលបានមកពីការវិនិយោគនៅក្នុងប្រទេសឧស្សាហកម្មផ្សេងទៀត ហើយដែលនាំឱ្យមានការផ្ទេរបរិមាណឯកតាសមមូលនៃការកាត់បន្ថយការបញ្ចេញឧស្ម័ន រវាងបណ្តាប្រទេសទាំងនោះ ។
- *យន្តការអភិវឌ្ឍន៍ស្អាត (CDM)* អនុញ្ញាតឱ្យមានគំរោងកាត់បន្ថយឧស្ម័នដែលជួយដល់ការអភិវឌ្ឍន៍ដោយចីរភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ហើយបង្កើតបានជាការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបានបញ្ជាក់ ដែលវិនិយោគិនអាចយកទៅប្រើប្រាស់ ។

បណ្តាយន្តការទាំងនេះផ្តល់ជូនប្រទេសទាំងឡាយ និងក្រុមហ៊ុនឯកជន នូវកាលានុវត្តភាព ដើម្បីកាត់បន្ថយឧស្ម័ននៅប្រទេសណាក៏បានលើពិភពលោក ពោលនៅកន្លែងណាដែលមានតំលៃទាប ហើយបន្ទាប់មកអាចទទួលយកការកាត់បន្ថយឧស្ម័ននេះ ចូលទៅក្នុងទិសដៅកាត់បន្ថយរបស់ខ្លួនផ្ទាល់ ។

យន្តការអាចលើកទឹកចិត្តឱ្យមានការវិនិយោគអន្តរជាតិ និងផ្តល់ធនធានសំខាន់ៗ សំរាប់កំនើនសេដ្ឋកិច្ចស្អាត នៅគ្រប់ទីកន្លែងនៅលើពិភពលោក តាមរយៈគំរោងកាត់បន្ថយការបញ្ចេញឧស្ម័ន ។ ជាពិសេស យន្តការអភិវឌ្ឍន៏ស្អាតមានគោលបំណងជួយដល់ប្រទេសកំពុងអភិវឌ្ឍន៏ ដើម្បីសំរេចការអភិវឌ្ឍន៏ដោយចិរភាព តាមរយៈការជំរុញការវិនិយោគដែលគិតគូរដល់វិស័យបរិស្ថាន ពីរដ្ឋាភិបាលនៃបណ្តាប្រទេសឧស្សាហកម្ម និងអ្នកជំនួញ ។

មូលនិធិ ដែលផ្តល់តាមរយៈគំរោងយន្តការអភិវឌ្ឍន៏ស្អាត ត្រូវតែជួយប្រទេសកំពុងអភិវឌ្ឍន៏ ឱ្យឈានដល់ទិសដៅអភិវឌ្ឍន៏សេដ្ឋកិច្ច សង្គម បរិស្ថាន និងការអភិវឌ្ឍន៏ប្រកបដោយចិរភាព ដូចជាខ្យល់អាកាស និងទឹកស្អាត ការកែលំអការប្រើប្រាស់ដី រួមជាមួយនិងផលប្រយោជន៏សង្គមផ្សេងទៀត ដូចជាការអភិវឌ្ឍន៏ជនបទ បង្កើតឱ្យមានការងារធ្វើ និងការកាត់បន្ថយភាពក្រីក្រ ហើយនៅក្នុងករណីជាច្រើន បានកាត់បន្ថយនូវភាពពឹងអាស្រ័យលើការនាំចូលឥន្ធនៈផូស៊ីល ។ បន្ថែមលើការជំរុញអាទិភាពវិនិយោគដែលមិនបំផ្លាញបរិស្ថាននៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៏ យន្តការអភិវឌ្ឍន៏ស្អាតផ្តល់នូវឱកាសដើម្បីធ្វើឱ្យរីកចំរើនព្រមគ្នានូវបញ្ហាអាកាសធាតុ ការអភិវឌ្ឍន៏ និងដោះស្រាយបញ្ហាបរិស្ថានក្នុងស្រុក ។ លទ្ធភាពទទួលអត្ថប្រយោជន៏បែបនេះនឹងផ្តល់នូវការលើកទឹកចិត្តយ៉ាងខ្លាំង ដើម្បីចូលរួមក្នុងយន្តការអភិវឌ្ឍន៏ស្អាត ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៏ ដែលតែងប្រឈមមុខនឹងតំរូវការសេដ្ឋកិច្ច និងសង្គមបន្ទាន់យ៉ាងច្រើនជំពូក ។

# សេចក្តីសង្ខេបស្តីពីយន្តការអភិវឌ្ឍន៍ស្អាត

## ការចូលរួម

យន្តការអភិវឌ្ឍន៍ស្អាតអនុញ្ញាតឱ្យភាគីនៅក្នុងឧបសម្ព័ន្ធទី 1 អនុវត្តគំរោងដែលកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ឬស្រូបយកឧស្ម័នផ្ទះកញ្ចក់ដោយការចាប់យកកាបូន ឬ "អាងស្រូបកាបូន" (ដោយមានកំរិត) នៅក្នុងទឹកដីរបស់ភាគីមិននៅក្នុងឧបសម្ព័ន្ធទី 1 ។ បន្ទាប់មក ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបានបញ្ជាក់ ហៅកាត់ថា CER ដែលទទួលបាន អាចត្រូវភាគីនៅក្នុងឧបសម្ព័ន្ធទី 1 ប្រើប្រាស់ ដើម្បីជួយឱ្យឈានដល់ទិសដៅកាត់បន្ថយការបញ្ចេញឧស្ម័នរបស់គេ ។ គំរោងយន្តការអភិវឌ្ឍន៍ស្អាត ត្រូវតែអនុម័តដោយភាគីចូលរួមទាំងអស់ ហើយនាំឆ្ពោះទៅរកការអភិវឌ្ឍន៍ដោយចីរភាព នៅក្នុងប្រទេសដែលជាម្ចាស់ផ្ទះ ព្រមទាំងនាំមកនូវផលប្រយោជន៍ពិតប្រាកដ អាចវាស់បាន និងយូរអង្វែង ក្នុងការសំរាលការប្រែប្រួលអាកាសធាតុ ។ ការកាត់បន្ថយឧស្ម័នត្រូវតែជាអ្វីដែលបន្ថែមថ្មី លើសពីអ្វីដែលអាចកើតមានក្នុងករណីដែលពុំមានគំរោង ។

ដើម្បីចូលរួមក្នុងយន្តការអភិវឌ្ឍន៍ស្អាត បណ្តាប្រទេសដែលចូលរួមត្រូវគោរពលក្ខណៈវិនិច្ឆ័យមួយចំនួន ។ ភាគីទាំងអស់ត្រូវឆ្លើយតបទៅនឹងការទាមទារជាមូលដ្ឋានចំនួន 3 គឺ : ការចូលរួមក្នុងយន្តការអភិវឌ្ឍន៍ស្អាតដោយស្ម័គ្រចិត្ត ការបង្កើតអាជ្ញាធរជាតិសំរាប់យន្តការអភិវឌ្ឍន៍ស្អាត (National CDM Authority) និងការផ្តល់សច្ចាប័នដល់ពិធីសារក្យូតូ ។ លើសពីនេះ បណ្តាប្រទេសឧស្សាហកម្មត្រូវមានលក្ខខណ្ឌបន្ថែមជាច្រើនទៀត ដូចជា : ការបង្កើតបរិមាណដែលបានកំណត់ (assigned amount) នៅក្រោមមាត្រាទី 3 នៃពិធីសារ, ប្រព័ន្ធជាតិសំរាប់គណនាឧស្ម័នផ្ទះកញ្ចក់, ការចុះបញ្ជីជាតិ, សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ប្រចាំឆ្នាំ, និងប្រព័ន្ធគណនេយ្យសំរាប់លក់ និងទិញការកាត់បន្ថយការបញ្ចេញឧស្ម័ន ។

**គំរោងដែលមានសិទ្ធិទទួលក្រោមយន្តការអភិវឌ្ឍន៍ស្អាត (Eligible Projects)**

យន្តការអភិវឌ្ឍន៍ស្អាតនឹងបញ្ចូលនូវបណ្តាគំរោង ដូចមាននៅក្នុងវិស័យខាងក្រោម :

- ការកែលំអប្រសិទ្ធិភាពថាមពលនៅកន្លែងប្រើប្រាស់
- ការកែលំអប្រសិទ្ធិភាពថាមពលនៅកន្លែងផលិត
- ថាមពលកើតឡើងវិញ
- ការផ្លាស់ប្តូរឥន្ធនៈ
- វិស័យកសិកម្ម (ការកាត់បន្ថយការបញ្ចេញឧស្ម័ន $CH_4$ និង $N_2O$)
- ដំណើរការឧស្សាហកម្ម (ការកាត់បន្ថយការបញ្ចេញឧស្ម័ន $CO_2$ ពីស៊ីម៉ងត៍ HFCs, PFCs, $SF_6$)
- គំរោងអាងស្រូបកាបូន ។ (មានតែការដាំព្រៃឈើ (afforestration) និងការស្តារព្រៃឈើឡើងវិញ (reforestation) ប៉ុណ្ណោះ) ។

ភាគីនៅក្នុងឧបសម្ព័ន្ធទី 1 មិនអាចប្រើប្រាស់ការកាត់បន្ថយឧស្ម័នដែលបានបញ្ជាក់ (CER) ដែលបានមកពីថាមពលនុយក្លេអ៊ែ ដើម្បីឈានដល់ទិសដៅរបស់គេឡើយ ។ លើសពីនេះទៀត នៅដំណាក់កាលកាតព្វកិច្ចទីមួយ (1008-1012) មានតែការដាំព្រៃឈើ និងការស្តារព្រៃឈើឡើងវិញប៉ុណ្ណោះ ដែលបានអនុញ្ញាតសំរាប់គំរោងអាងស្រូបកាបូន ហើយភាគីនៅក្នុងឧបសម្ព័ន្ធទី 1 អាចបន្ថែម CER ទទួលបានពីគំរោងអាងស្រូបកាបូន ទៅលើបរិមាណកំណត់របស់ខ្លួនត្រឹម 1% នៃការបញ្ចេញឧស្ម័នគោល (baseline emission) សំរាប់រាល់ឆ្នាំ ក្នុងអំឡុងពេលកិច្ចសន្យា ។ គោលការណ៍ណែនាំបន្ថែមទៀត សំរាប់គំរោងអាងស្រូបការបូននឹងត្រូវបង្កើត ដើម្បីធានាថា គំរោងទាំងនោះមានការគិតគូរដល់ផ្នែកបរិស្ថាន ។

ដើម្បីធ្វើឱ្យគំរោងខ្នាតតូចមួយអាចប្រកួតប្រជែងជាមួយនឹងគំរោងធំៗបាន កិច្ចព្រមព្រៀងម៉ារ៉ាកេសបង្កើតនូវបែបបទងាយមួយ សំរាប់គំរោងខ្នាតតូច ដែលមានវិធានសំរាប់សិទ្ធិចូលរួមងាយជាង ដូចជា : គំរោងថាមពលកើតឡើងវិញរហូតដល់ 15 MW,

គំរោងប្រសិទ្ធិភាពថាមពលដែលកាត់បន្ថយការប្រើប្រាស់ថាមពលនៅកន្លែងផលិត ឬនៅកន្លែងប្រើប្រាស់រហូតដល់ 15 ហ្គីហ្គាវ៉ាត់ម៉ោង ក្នុងមួយឆ្នាំ, និងគំរោងផ្សេងៗទៀត ដែលកាត់បន្ថយ ទាំងការបញ្ចេញ និងបញ្ចេញឧស្ម័នតិចជាង 15 គីឡូតោននៃសមមូលឧស្ម័នកាបូនិច ក្នុងមួយឆ្នាំ ។ ក្រុមប្រឹក្សាប្រតិបត្តិត្រូវបានគេស្នើឱ្យធ្វើការកំនត់ពីរបៀប និងនីតិវិធីសំរាប់បែបទងាយនេះ ហើយនឹងដាក់ជូនទៅកិច្ចប្រជុំលើកទី 8 របស់បណ្តាភាគីនៃអនុសញ្ញា ដែលនឹងប្រារព្ធទៅ នៅទីក្រុងញូវដេលី ក្នុងខែសីហា ឆ្នាំ 2002 ។

## ការធ្វើហិរញ្ញប្បទាន (Financing)

មូលនិធិសាធារណៈសំរាប់គំរោងយន្តការអភិវឌ្ឍន៍ស្អាត មិនមែនជាទឹកប្រាក់ដែលបានមកពីការបង្វែរមូលនិធិសំរាប់ជំនួយអភិវឌ្ឍន៍ផ្លូវការ (official development assistance: ODA) ទេ ។ លើសពីនេះ CER ដែលបានបង្កើតដោយគំរោង CDM នឹងជាកម្មវត្ថុនៃការហូតពន្ធ ដែលគេហៅថា "ភាគហ៊ុនចំណូល " (share of the proceeds) ស្មើនឹង 2% សំរាប់បង់ចូលទៅក្នុងមូលនិធិសំរាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដែលទើបតែបានបង្កើតឡើងថ្មីៗ ដើម្បីជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលទទួលរងផលប៉ះពាល់ ក្នុងការបន្សាំទៅនឹងឥទ្ធិពលអាក្រក់នៃការប្រែប្រួលអាកាសធាតុ ។

ការហូតពន្ធមួយទៀតទៅលើ CER នឹងរួមចំណែកដល់ចំណាយរដ្ឋបាលរបស់ CDM ។ ពន្ធលើគំរោង CDM នៅក្នុងប្រទេសក្រីក្របំផុតត្រូវបានគេលើកលែង សំរាប់ការបន្សាំ និងចំណាយរដ្ឋបាល ដើម្បីជំរុញរបាយនៃគំរោងឱ្យបានស្មើភាព ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ ។

## ក្រុមប្រឹក្សាប្រតិបត្តិ (The Executing Board)

CDM ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាប្រតិបត្តិមួយ ដែលអនុវត្តការងារនៅក្រោមអំណាចរបស់ភាគីនៃអនុសញ្ញា ។ ក្រុមប្រឹក្សាប្រតិបត្តិនេះមានសមាជិកចំនួន 10 ដែលរួមមានតំណាងមួយនាក់ មកពីទ្វីបនីមួយៗ នៃទ្វីបផ្លូវការទាំង 5 របស់អង្គការសហ-

ប្រជាជាតិ (អាហ្វ្រិច អាស៊ី អាមេរិចឡាទីននិងការ៉ាប៊ីន អឺរ៉ុបកណ្តាលនិងខាងកើត និងក្រុមប្រទេស OECD) តំណាងមួយនាក់មកពីប្រទេសកំពុងអភិវឌ្ឍន៍ដែលជាកោះតូចៗ និងតំណាងពីរនាក់មកពីភាគីនៅក្នុងឧបសម្ព័ន្ធទី 1 (Annex I Parties) និងពីរនាក់មកពីភាគីមិននៅក្នុងឧបសម្ព័ន្ធទី 1 (non-Annex I Parties) ។ ក្រុមប្រឹក្សាប្រតិបត្តិបានបើកសម័យប្រជុំទីមួយរបស់ខ្លួន នៅទីក្រុងម៉ារ៉ាកេស នាខែវិច្ឆិកា ឆ្នាំ 2001 ដែលកំណត់នូវការចាប់ផ្តើមរបស់ CDM ។

ក្រុមប្រឹក្សាប្រតិបត្តិផ្តល់ការទទួលស្គាល់ជាផ្លូវការនូវស្ថាប័នឯករាជ្យ ដែលគេហៅថា អង្គភាពប្រតិបត្តិ (operational entities) ដែលជាអ្នកផ្តល់សុពលភាពដល់គំរោង CDM ផ្ទៀងផ្ទាត់លទ្ធផលនៃការកាត់បន្ថយការបញ្ចេញឧស្ម័ន និងបញ្ជាក់ថា ការកាត់បន្ថយការបញ្ចេញឧស្ម័នទាំងនោះជា CER ។ កិច្ចការគន្លឹះមួយទៀត គឺការរៀបចំការិយាល័យចុះបញ្ជី CDM ដែលជាអ្នកចេញ CER ថ្មី គ្រប់គ្រងគណនេយ្យមួយសំរាប់ CER ដែលហួតពន្ធបានសំរាប់ការបន្សាំ និងការចំណាយផ្នែករដ្ឋបាល និងរក្សាទុកគណនេយ្យសំរាប់រាល់ភាគីមិននៅក្នុងឧបសម្ព័ន្ធទី 1 ដែលធ្វើជាម្ចាស់ផ្ទះនៃគំរោង CDM ។

## ការកំណត់ និងការរៀបចំគំរោង (Project Identification and Formulation)

ជំហានដំបូងនៅក្នុងវដ្តគំរោង CDM គឺការកំណត់ និងការរៀបចំគំរោង CDM ដែលមានសក្តានុពល ។ គំរោង CDM ត្រូវតែប្រាកដនិយម អាចវាស់វែងបាន និងជាគំរោងបន្ថែម ។ ដើម្បីបង្កើតភាពបន្ថែម (additionality) ការបញ្ចេញឧស្ម័នរបស់គំរោងត្រូវប្រៀបធៀបជាមួយនឹងការបញ្ចេញឧស្ម័ន នៃករណីយោងដ៏សមស្របមួយ ដែលគេកំណត់ថាជាលក្ខខណ្ឌគោល (baseline) ។ ការកំណត់លក្ខខណ្ឌគោលត្រូវធ្វើឡើងដោយអ្នកចូលរួមក្នុងគំរោង អនុលោមតាមវិធីសាស្ត្រដែលបានអនុម័ត អនុលោមតាមលក្ខណៈដោយឡែករបស់គំរោង ។ វិធីសាស្ត្រគោលទាំងនេះកំពុងត្រូវបានរៀបចំ ដោយផ្អែកទៅលើវិធីទាំង 3 នៅក្នុងកិច្ចព្រមព្រៀងទីក្រុងម៉ារ៉ាកេស គឺ :

- ការបញ្ចេញឧស្ម័នបច្ចុប្បន្ន ឬពីអតីតកាល
- ការបញ្ចេញឧស្ម័នពីបច្ចេកវិទ្យាមួយ ដែលតំណាងឱ្យការវិនិយោគមានការទាក់ទាញផ្នែកសេដ្ឋកិច្ច
- ការបញ្ចេញឧស្ម័នមធ្យមនៃសកម្មភាពគំរោងស្រដៀងគ្នា ដែលអនុវត្តក្នុងរយៈពេល 5 ឆ្នាំមុន ក្រោមស្ថានភាពប្រហាក់ប្រហែលគ្នា ហើយដែលការអនុវត្តន៍របស់គំរោងស្ថិតនៅក្នុងចំណោមគំរោងល្អបំផុត 20% នៃប្រភេទគំរោងនោះ ។

គំរោង CDM ត្រូវមានផែនការត្រួតពិនិត្យមួយ ដើម្បីប្រមូលទិន្នន័យការបញ្ចេញឧស្ម័នពិត ។ ផែនការត្រួតពិនិត្យ ដែលជាមូលដ្ឋាននៃការផ្ទៀងផ្ទាត់នៅអនាគត ត្រូវផ្តល់សេចក្តីទុកចិត្តថា ការកាត់បន្ថយការបញ្ចេញឧស្ម័ន និងទិសដៅរបស់គំរោងផ្សេងទៀត នឹងត្រូវសំរេចបាន ហើយអាចមានលទ្ធភាពត្រួតពិនិត្យទៅលើភាពប្រថុយប្រថាន ដែលមាននៅជាមួយការបញ្ចេញឧស្ម័នគោល និងការបញ្ចេញឧស្ម័នពីគំរោង ។ ផែនការត្រួតពិនិត្យអាចត្រូវបង្កើតឡើងដោយអ្នកធ្វើគំរោង ឬដោយទីភ្នាក់ងារជំនាញ ។ ការបង្កើតផែនការគោល និងផែនការត្រួតពិនិត្យ ត្រូវធ្វើឡើង ដោយយោងទៅតាមវិធីសាស្ត្រ ដែលបានអនុម័តហើយ ។ ប្រសិនបើអ្នកចូលរួមក្នុងគំរោងជ្រើសរើសវិធីសាស្ត្រថ្មីណាមួយ វិធីសាស្ត្រនោះត្រូវតែបានទទួលការអនុញ្ញាត និងចុះបញ្ជីដោយក្រុមប្រឹក្សាប្រតិបត្តិ ។ អ្នកចូលរួមក្នុងគំរោងត្រូវជ្រើសរើសអំឡុងពេលឥណទាន (crediting period) 10 ឆ្នាំ ឬ 7 ឆ្នាំ ដោយមានលទ្ធភាពអាចបន្តបាន 2 ដង ( អតិបរមា 21 ឆ្នាំ) ។

## វដ្តគំរោង CDM




*វដ្តគំរោង CDM ដូចមានបង្ហាញនៅរូបភាពខាងលើ មាន 7 ដំណាក់កាលជាមូលដ្ឋាន : ការរៀបចំនិងបង្កើតគំរោង, ការអនុម័តនៅថ្នាក់ជាតិ, ការផ្តល់សុពលភាព/ការចុះបញ្ជី, ការផ្តល់ហិរញ្ញប្បទានដល់គំរោង, ការត្រួតពិនិត្យ, ការផ្ទៀងផ្ទាត់/បញ្ជាក់, ការចេញឱ្យ CER ។ សកម្មភាពបួនដំបូងត្រូវធ្វើមុនការនុវត្តគំរោង ដោយឡែកសកម្មភាពបីបន្ទាប់ ត្រូវអនុវត្តក្នុងអំឡុងពេលដំណើរការរបស់គំរោង ។*

## ការអនុម័តនៅថ្នាក់ជាតិ (National Approval)

ប្រទេសទាំងអស់ដែលមានបំណងចូលរួមក្នុង CDM ត្រូវចាត់តាំងបង្កើតអាជ្ញាធរជាតិ CDM មួយ ដើម្បីវាយតំលៃ និងអនុម័តគំរោង ព្រមទាំងបំពេញនាទីជាចំណុចទាក់ទង ។ ទោះបីទំរង់ការអន្តរជាតិបានផ្តល់គោលការណ៍ណែនាំទូទៅស្តីពីការបញ្ចេញឧស្ម័នគោល និងការកាត់បន្ថយឧស្ម័នបន្ថែមក៏ដោយ ក៏ប្រទេសកំពុងអភិវឌ្ឍន៍នីមួយៗ មានការទទួលខុសត្រូវ ដើម្បីកំណត់លក្ខណៈវិនិច្ឆ័យថ្នាក់ជាតិ សំរាប់អនុម័តគំរោងដែរ ។ ដោយសហការជាមួយនឹងអ្នកវិនិយោគ ប្រទេសជាម្ចាស់ផ្ទះត្រូវរៀបចំឯកសាររៀបចំគំរោងមួយដែលមានរចនាសម្ព័ន្ធដូចខាងក្រោម :

- ការពិពណ៌នាទូទៅអំពីគំរោង
- ការពិណ៌នាអំពីវិធីសាស្រ្តគោល
- កាលបរិច្ឆេទ និងអំឡុងពេលឥណទាន
- ផែនការ និងវិធីសាស្រ្តត្រួតពិនិត្យ
- ការគណនាការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមប្រភពបញ្ចេញ
- សេចក្តីបំភ្លឺអំពីផលប៉ះពាល់បរិស្ថាន
- មតិយោបល់របស់អ្នកពាក់ព័ន្ធ ។

អាជ្ញាធរជាតិ CDM ចាំបាច់ត្រូវចេញសេចក្តីថ្លែងការណ៍ ដែលបញ្ជាក់ថារដ្ឋាភិបាលចូលរួមក្នុងគំរោងដោយការស្ម័គ្រចិត្ត និងបញ្ជាក់ថា សកម្មភាពរបស់គំរោងជួយដល់ប្រទេសជាម្ចាស់ផ្ទះ ដើម្បីសំរេចនូវការអភិវឌ្ឍន៍ដោយចីរភាព ។

## ការផ្តល់សុពលភាព និងការចុះបញ្ជី (Validation and Registration)

អង្គភាពប្រតិបត្តិដែលបានជ្រើសតាំងរួច ត្រូវពិនិត្យឯកសាររៀបចំគំរោង ហើយបន្ទាប់ពីទទួលមតិយោបល់ជាសាធារណៈ អង្គភាពនេះត្រូវសំរេចថា តើត្រូវផ្តល់សុពលភាពឱ្យគំរោងនេះ ឬអត់ ។ អង្គភាពប្រតិបត្តិទាំងនោះគឺជាក្រុមហ៊ុនឯកជន ដូចជាក្រុមហ៊ុនសវនកម្មនិងគណនេយ្យ, ក្រុមហ៊ុនពិគ្រោះយោបល់, និងក្រុមហ៊ុនច្បាប់ ដែលមានសមត្ថភាព

អាចធ្វើការវាយតំលៃលើការកាត់បន្ថយការបញ្ចេញឧស្ម័នដោយឯករាជ្យ និងអាចទុកចិត្តបាន ។ នៅពេលផ្តល់សុពលភាពហើយ អង្គភាពប្រតិបត្តិត្រូវបញ្ជូនឯកសារទៅក្រុមប្រឹក្សាប្រតិបត្តិសំរាប់ការចុះបញ្ជីជាផ្លូវការ ។

## ការត្រួតពិនិត្យ ការផ្ទៀងផ្ទាត់ និងការបញ្ជាក់ (Monitoring, Verification and Certification)

សមាសភាគកាបូននៃគំរោងកាត់បន្ថយឧស្ម័នមួយ មិនអាចទទួលបានតំលៃទីផ្សារកាបូនអន្តរជាតិទេ ប្រសិនបើមិនបានដាក់ឱ្យឆ្លងកាត់ដំណើរការផ្ទៀងផ្ទាត់ ដែលបានរៀបចំឡើងជាពិសេស ដើម្បីវាស់វែង និងធ្វើសវនកម្មដល់សមាសភាគកាបូននោះ ។ ដូច្នេះ នៅពេលអនុវត្តគំរោង អ្នកចូលរួមត្រូវរៀបចំរបាយការណ៍ត្រួតពិនិត្យមួយ ដោយមានបញ្ចូលការប៉ាន់ប្រមាណនូវ CERs ដែលបានបង្កើតឡើង ហើយដាក់ជូនទៅអង្គភាពប្រតិបត្តិណាមួយដើម្បីផ្ទៀងផ្ទាត់ ។

ការផ្ទៀងផ្ទាត់គឺជាការកំណត់មុន និងក្រោយ ដោយឯករាជ្យនៃអង្គភាពប្រតិបត្តិលើការកាត់បន្ថយឧស្ម័ន ដែលបានត្រួតពិនិត្យរួចហើយ ។ អង្គភាពប្រតិបត្តិត្រូវធានាថា CER ត្រូវបានទទួលស្របតាមគោលការណ៍ណែនាំ និងលក្ខខណ្ឌ ដែលគេបានព្រមព្រៀងនៅក្នុងពេលផ្តល់សុពលភាពដល់គំរោងដំបូង ។ បន្ទាប់ពីការពិនិត្យពិច័យដ៏ល្អិតល្អន់រួចមក អង្គភាពប្រតិបត្តិនឹងធ្វើរបាយកាណ៍ផ្ទៀងផ្ទាត់មួយ បន្ទាប់មកបញ្ជាក់នូវបរិមាណ CER ដែលបានពីគំរោង CDM ។

ការបញ្ជាក់គឺជាការធានាជាប់រងជាលាយលក្ខណ៍អក្សរ ថាគំរោងសំរេចបាននូវការកាត់បន្ថយឧស្ម័នដូចបានបញ្ជាក់រួចហើយ ។ របាយការណ៍បញ្ជាក់ក៏មាននូវសំណើមួយសំរាប់ការចេញបញ្ជាក់ CER ផងដែរ ។ ប្រសិនបើអ្នកចូលរួមគំរោងណាមួយ ឬសមាជិកក្រុមប្រឹក្សាប្រតិបត្តិ 3 នាក់ មិនស្នើឱ្យពិនិត្យឡើងវិញក្នុងរយៈពេល 15 ថ្ងៃ នោះក្រុមប្រឹក្សាប្រតិបត្តិ នឹងណែនាំឱ្យការិយាល័យចុះបញ្ជី CDM ចេញជូននូវ CER ។

# តំលៃ និងអត្ថប្រយោជន៍ជាតិ

គោលការណ៍ជាមូលដ្ឋាននៃ CDM គឺមានភាពសាមញ្ញ : ប្រទេសអភិវឌ្ឍន៍អាចមានឱកាសវិនិយោគ ក្នុងការកាត់បន្ថយឧស្ម័ននៅប្រទេសកំពុងអភិវឌ្ឍន៍ដែលចំណាយតិច ហើយទទួលឥណទានសំរាប់ការកាត់បន្ថយការបញ្ចេញឧស្ម័ន សំរាប់យកទៅទូទាត់កាតព្វកិច្ចកាត់បន្ថយ នៅក្នុងព្រំដែនប្រទេសរបស់គេ ។ នៅពេល CDM កាត់ចំណាយនៃការអនុវត្តន៍តាមពិធីសារសំរាប់ប្រទេសអភិវឌ្ឍន៍ ប្រទេសកំពុងអភិវឌ្ឍន៍ក៏ទទួលបានអត្ថប្រយោជន៍ផងដែរ ក្នុងទំរង់ជាកំណើននៃលំហូរនៃការធ្វើវិនិយោគ និងពិលក្ខខណ្ឌដែលថា ការវិនិយោគទាំងនោះ ជំរុញឱ្យសំរេចទិសដៅអភិវឌ្ឍន៍ដោយចីរភាព ។ CDM លើកទឹកចិត្តប្រទេសកំពុងអភិវឌ្ឍន៍ឱ្យចូលរួម តាមរយៈការសន្យាថាការអភិវឌ្ឍន៍ និងគំនិតផ្តួចផ្តើមជាអាទិភាព នឹងត្រូវបានដោះស្រាយជាផ្នែកមួយនៃគំរោង ។ នេះមានន័យថា មានតែតាមរយៈការអភិវឌ្ឍន៍យូរអង្វែងប៉ុណ្ណោះ ដែលធ្វើប្រទេសទាំងអស់អាចដើរតួក្នុងកិច្ចការពារអាកាសធាតុបាន ។

សំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ CDM អាច :

- ទាក់ទាញមូលធនសំរាប់គំរោង ដែលជួយនៅក្នុងការផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចមួយ ដែលរុងរឿង ហើយប្រើកាបូនតិច
- លើកទឹកចិត្ត និងអនុញ្ញាតឱ្យមានការចូលរួមយ៉ាងសកម្មនៃផ្នែកឯកជន និងផ្នែករដ្ឋ
- ផ្តល់មធ្យោបាយសំរាប់ផ្ទេរបច្ចេកវិទ្យា ប្រសិនបើការវិនិយោគត្រូវបានបញ្ចូលទៅក្នុងគំរោងដែលជំនួសបច្ចេកវិទ្យាចាស់ៗ និងគ្មានប្រសិទ្ធិភាព ដែលប្រើប្រាស់ឥន្ធនៈផូស៊ីល
- ជួយកំនត់អាទិភាពនៃការវិនិយោគនៅក្នុងគំរោង ដែលឆ្លើយតបនឹងទិសដៅអភិវឌ្ឍន៍ដោយចីរភាព ។

ជាពិសេស CDM អាចជួយដល់ទិសដៅអភិវឌ្ឍន៍ដោយចីរភាពរបស់ប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈ :

- ការផ្ទេរបច្ចេកវិទ្យា និងធនធានហិរញ្ញវត្ថុ
- វិធីផលិតថាមពលដោយនិរន្តរភាព

- ការបង្កើនប្រសិទ្ធិភាពថាមពល និងការសន្សំសំចៃថាមពល
- ការកាត់បន្ថយភាពក្រីក្រ តាមរយៈប្រាក់ចំណូល និងការបង្កើនការងារ
- អត្ថប្រយោជន៍ផ្នែកបរិស្ថាននៅនឹងកន្លែង ។

ការជំរុញឱ្យមានកំនើនសេដ្ឋកិច្ច នាំឱ្យមានទាំងការគំរាមកំហែង ទាំងកាលានុវត្ត-ភាពសំរាប់ការអភិវឌ្ឍន៍ដោយចីរភាព ។ នៅពេលដែលគុណភាពបរិស្ថានគឺជាធាតុមួយដ៏សំខាន់សំរាប់ដំណើរការអភិវឌ្ឍន៍ ក្នុងការអនុវត្តន៍ជាក់ស្តែង មានភាពតានតឹងជាច្រើនរវាងទិសដៅសេដ្ឋកិច្ច និងបរិស្ថាន ។ ប្រសិនបើការអភិវឌ្ឍន៍ប្រព្រឹត្តទៅតាមបែបប្រពៃណី នោះកំណើននៃលទ្ធភាពប្រើប្រាស់ថាមពល និងការផ្តល់នូវសេវាកម្មសេដ្ឋកិច្ចជាមូលដ្ឋាន អាចបណ្តាលឱ្យមានការខូចខាតដល់បរិស្ថានយូរអង្វែង ទាំងនៅនឹងកន្លែង ទាំងនៅក្នុងពិភពលោក ។ ប៉ុន្តែ តាមរយៈការធ្វើផែនការទិសដៅផ្សេងគ្នា និងការផ្តល់ជំនួយបច្ចេកទេសក៏ដូចជាជំនួយហិរញ្ញវត្ថុដើម្បីអនុវត្តតាម បញ្ហាចំបងៗជាច្រើនអាចត្រូវជៀសវាងបាន ។

បើធ្វើការប្រៀបធៀបគំរោង CDM ជាមួយនិងគំរោងផ្សេងដែលអាចកើតឡើងជាធម្មតា នោះយើងឃើញច្បាស់ថា គំរោង CDM ភាគច្រើននឹងមិនត្រឹមតែនាំមកនូវអត្ថប្រយោជន៍ផ្នែកកាត់បន្ថយកាបូនប៉ុណ្ណោះទេ វាថែមទាំងបង្កើតអត្ថប្រយោជន៍សង្គម និងបរិស្ថានជាច្រើនទៀតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ អត្ថប្រយោន៍នៃការអភិវឌ្ឍន៍ដោយចីរភាពរួមមាន ការកាត់បន្ថយការបំពុលទឹក និងខ្យល់តាមរយៈកាត់បន្ថយការប្រើប្រាស់ឥន្ទនៈផូស៊ីល ជាពិសេសគឺធ្យូងថ្ម, ការកែលំអលទ្ធភាពប្រើប្រាស់ទឹក, កាត់បន្ថយសំណឹកដី និងការពារជីវៈចំរុះ ។ ចំពោះអត្ថប្រយោជន៍សង្គមវិញ គំរោងជាច្រើនអាចបង្កើតកាលា-នុវត្តភាពឱ្យមានការងារធ្វើ នៅក្នុងតំបន់ដែលគំរោងត្រូវបានអនុវត្ត ឬសំរាប់ក្រុមមនុស្សណាមួយ និងលើកកំពស់ការផ្គត់ផ្គង់ថាមពលនៅនឹងកន្លែងឱ្យបានគ្រប់គ្រាន់ ។ ដូច្នេះ ការកាត់បន្ថយកាបូន និងទិសដៅអភិវឌ្ឍន៍ដោយចីរភាព អាចត្រូវអនុវត្តទៅបានក្នុងពេលជាមួយគ្នា ។

ជំរើសជាច្រើននៅក្រោម CDM អាចបង្កើតអត្ថប្រយោជន៍សំខាន់ៗរួមគ្នាជាច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីដោះស្រាយបញ្ហាបរិស្ថានក្នុងស្រុក និងក្នុងតំបន់

ព្រមទាំងជំរុញវឌ្ឍនភាពសង្គម ។ ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ដែលផ្តល់អាទិភាពដល់តំរូវការអភិវឌ្ឍន៍សេដ្ឋកិច្ច និងបរិស្ថានបន្ទាន់ អត្ថប្រយោជន៍បន្ទាប់បន្សំសំខាន់ៗអាចផ្តល់នូវការលើកទឹកចិត្តដ៏រឹងមាំ សំរាប់ចូលរួមក្នុង CDM ។

# ការកសាងយុទ្ធសាស្ត្រនៃយន្តការអភិវឌ្ឍន៍ស្អាតថ្នាក់ជាតិ

## ការវាយតំលៃផលប្រយោជន៍ និងអាទិភាពថ្នាក់ជាតិ

CDM ផ្តល់នូវកាលានុវត្តភាពមួយ ដើម្បីបញ្ជូនធនធានទាំងឡាយ ឆ្ពោះទៅរកបណ្តាគំរោងដែលមានលក្ខណៈល្អបំផុត សំរាប់ការអភិវឌ្ឍន៍ប្រទេសជាតិដោយចីរភាព ។ ដូច្នេះ លក្ខណៈវិនិច្ឆ័យចំពោះគំរោង CDM ត្រូវអាស្រ័យទៅលើទិសដៅអភិវឌ្ឍន៍ដោយចីរភាព ដែលអាចកំណត់បានតាមរយៈទិសដៅ និងគោលនយោបាយ ដែលបានបង្កើតរួចជាស្រេចសំរាប់ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចក្នុងវិស័យពាក់ពន្ធ័ផ្សេងៗ ដូចជាថាមពល ការប្រែប្រួលការប្រើប្រាស់ដី និងគមនាគមន៍ ។ នៅថ្នាក់ជាតិ កម្មវិធីអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ឬផែនការបរិស្ថានជាតិ ប្រហែលជាមានរួចជាស្រេច នៅក្នុងវិស័យពាក់ពន្ធ័ ដូចជាគោលនយោបាយព្រៃឈើ ថាមពលកើតឡើងវិញ និងបច្ចេកវិទ្យាស្អាត ។

## ការកសាងការគាំទ្រសំរាប់ CDM របៀបដោះស្រាយដោយមានការចូលរួម (Participatory Approach)

បញ្ហាប្រឈមមុខមួយ ក្នុងចំណោមទិដ្ឋភាពជាច្រើននៃការកសាងយុទ្ធសាស្ត្រជាតិ CDM គឺការជំរុញឱ្យមានការគាំទ្រយ៉ាងសកម្ម ពីគ្រប់ស្ថាប័នទាំងអស់របស់សង្គម (សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នរដ្ឋ និងឯកជន) និងវិស័យសេដ្ឋកិច្ចសំខាន់ផ្សេងៗទៀត (ដូចជាឧស្សាហកម្ម ថាមពល កសិកម្ម រុក្ខកម្ម) ។ យុទ្ធសាស្ត្រ CDM មួយ ដែលមានជោគជ័យ នឹងតំរូវឱ្យមានការគាំទ្រជាផ្លូវការពីរដ្ឋាភិបាល តាមរយៈការផ្តល់សច្ចាប័នដល់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) និងពិធីសារក្យូតូ ក៏ដូចជាការរៀបចំអាជ្ញាធរជាតិដើម្បីអនុម័តគំរោង CDM ។ លើសពីនេះរដ្ឋាភិបាលក៏នឹងដើរតួយ៉ាងសំខាន់ផងដែរ នៅក្នុងកិច្ចសហការជាមួយផ្នែកឯកជន ដើម្បីជំរុញឱ្យមានទីផ្សារសំរាប់សំណើគំរោង CDM ដល់អ្នកវិនិយោគ ។

វិស័យឯកជនអាចជួយធានាឱ្យមានការយកចិត្តទុកដាក់លើប្រសិទ្ធិភាព និងការរៀបចំបណ្តាវិធានច្បាស់លាស់ និងងាយ ។ ការអនុញ្ញាតឱ្យមានការចូលរួមពីផ្នែកឯកជននៅក្នុងដំណើរការកសាងស្ថាប័ន លើកទឹកចិត្តឱ្យមានការិយាធិបតេយ្យតិច និងនាំឱ្យមានរបៀបដោះស្រាយដែលផ្តោះទៅរកលទ្ធផល នៅក្នុងនីតិវិធី ។ ផ្នែកឯកជនមានសារៈសំខាន់ណាស់សំរាប់ជំរុញ CDM ដោយហេតុថា អ្នកវិនិយោគតែងស្វែងរកមធ្យោបាយកាត់បន្ថយការបញ្ចេញឧស្ម័ន ដែលមានប្រសិទ្ធិភាពសេដ្ឋកិច្ច ។

អង្គការមិនមែនរដ្ឋាភិបាល (NGOs) គួរត្រូវដាក់បញ្ចូលនៅក្នុងការរៀបចំ និងការអនុវត្តន៍យុទ្ធសាស្ត្រ ពីព្រោះបណ្តាអង្គការទាំងនេះជំរុញឱ្យមានការយកចិត្តទុកដាក់លើបរិស្ថាន និងសង្គមនៅក្នុងរបៀបវារៈស្ថាប័ន ។ NGOs អាចជាឃ្លាំងនៃជំនាញវិទ្យាសាស្ត្រដ៏មានតំលៃ និងជំនាញបច្ចេកទេស ក្នុងការរៀបចំ និងវាយតំលៃគំរោង ។

ការបញ្ចូលផ្នែកទាំងនេះពុំមែនជារឿងងាយស្រួលទេ ។ រដ្ឋាភិបាលខ្លះអាចពេញចិត្តធ្វើទំនាក់ទំនងការងារល្អជាមួយ NGOs និងផ្នែកឯកជន ហើយអនុញ្ញាតឱ្យផ្នែកទាំងនេះបែងចែកការទទួលខុសត្រូវ និងធ្វើការរួមគ្នា ។ ទោះជាយ៉ាងនេះក៏ដោយ រដ្ឋាភិបាលនៃប្រទេសផ្សេងទៀត មានទំនាក់ទំនងឃ្លាតឆ្ងាយជាមួយវិស័យផ្សេងៗ ធ្វើឱ្យមានការលំបាកក្នុងការឈានទៅរកគោលដៅរួម ។ នៅក្នុងគ្រប់ករណី របៀបដោះស្រាយត្រូវតែសមស្របទៅនឹងស្ថានភាពជាក់ស្តែងរបស់ជាតិ ។

## រចនាសម្ព័ន្ធស្ថាប័នជាតិសំរាប់អនុវត្តគំរោង CDM

អាជ្ញាធរជាតិ CDM គឺជាអង្គភាពរបស់ប្រទេសជាម្ចាស់ផ្ទះ ឬស្ថាប័នដែលវាយតំលៃបណ្តាគំរោង CDM ដែលមានសក្តានុពល និងផ្តល់នូវសំណើជាលាយលក្ខណ៍អក្សរបញ្ជាក់ថា សកម្មភាពគំរោងជាការស្ម័គ្រចិត្ត អនុលោមតាមលក្ខណៈវិនិច្ឆ័យរបស់ជាតិ និងអន្តរជាតិដោយ ហើយជួយឱ្យសំរេចដល់ការអភិវឌ្ឍន៍ដោយចីរភាពនៅក្នុងប្រទេសជាម្ចាស់ផ្ទះ ។

អាជ្ញាធរជាតិ CDM ត្រូវមានទំនាក់ទំនងដោយចំហជាមួយស្ថាប័នរដ្ឋាភិបាល នៃវិស័យដែលពាក់ព័ន្ធជាមួយ CDM ។ ជាញឹកញាប់ ការត្រួតពិនិត្យបច្ចេកទេសលើគំរោង អាចជាប់ទាក់ទងជាមួយក្រសួង ឬការិយាល័យទាំងឡាយ នៃវិស័យដែលពាក់ព័ន្ធ (ថាមពល ធនធានធម្មជាតិ បរិស្ថាន ។ល។) ។ សំណើគំរោង CDM ក៏ជាប់ពាក់ព័ន្ធផងដែរជាមួយ ក្រសួងការបរទេស ដោយសារក្រសួងនេះតែងតែដើរតួជាចំនុចបង្គោលរបស់អនុសញ្ញា ក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC Focal Point) ។

## ការវាយតំលៃ និងការអនុម័ត

ដំណើរការវាយតំលៃល្អនឹងបង្កើនលទ្ធភាពបង្កើតបណ្តុំគំរោង ដែលអាចទទួល សុពលភាព និងបញ្ជាក់ថា ជាគំរោង CDM ប្រកបដោយជោគជ័យ ហើយកាត់បន្ថយភាព ប្រថុយប្រថានពិតប្រាកដ ឬដែលអាចមាន របស់អ្នកវិនិយោគជាតិ និងបរទេស ក្នុងការ រៀបចំ និងអនុវត្តន៍គំរោងកាត់បន្ថយកាបូន ។ វាក៏អាចបង្កើតការលើកទឹកចិត្តផងដែរ សំរាប់ប្រភេទគំរោងពិសេសដោយឡែក ឬសំរាប់វិស័យអាទិភាព ។ របៀបវាយតំលៃអាច មាននាទីជាតំរងសំខាន់ ដើម្បីធានាថា គំរោងដើរតាមទិសដៅរបស់ CDM ហើយស្របទៅ តាមគោលនយោបាយ យុទ្ធសាស្ត្រ និងអាទិភាពរបស់ប្រទេសជាតិ ។

*លក្ខណៈវិនិច្ឆ័យអន្តរជាតិ :* ចំណុចចាប់ផ្តើមក្នុងដំណើរការវាយតំលៃគឺថា ជាដំបូងគំរោង CDM មួយត្រូវបំពេញតាមលក្ខណៈវិនិច្ឆ័យដែលបានយល់ព្រមជាអន្តរជាតិ ។ មាត្រាទី 12 នៃពិធីសារក្យូតូកំនត់នូវលក្ខណៈវិនិច្ឆ័យទទួលសិទ្ធិចំបងចំនួន 3 សំរាប់គំរោង CDM :

- គំរោងត្រូវជួយដល់ភាគីមិននៅក្នុងឧបសម្ព័ន្ធទី 1 " នៅក្នុងការសំរេចការអភិវឌ្ឍន៍ ដោយចីរភាព និងរួមចំណែកដល់ទិសដៅចុងក្រោយរបស់អនុសញ្ញា "
- គំរោងត្រូវនាំមកនូវលទ្ធផលជា "អត្ថប្រយោជន៍ពិតប្រាកដ អាចវាស់បាន និងយូរ អង្វែង ចំពោះការកាត់បន្ថយការប្រែប្រួលអាកាសធាតុ "

- គំរោងត្រូវនាំមកនូវលទ្ធផលជា " ការកាត់បន្ថយការបញ្ចេញឧស្ម័ន ដែលជាការបន្ថែម លើអ្វី ដែលអាចកើតមាន នៅពេលអវត្តមាននៃសកម្មភាពគំរោងដែលបានបញ្ជាក់ " ។

កិច្ចព្រមព្រៀងម៉ារ៉ាកេសកំនត់លក្ខណៈវិនិច្ឆ័យបន្ថែមទៀត ដែលត្រូវតែអនុវត្ត ដោយគំរោង CDM ដែលមានសក្តានុពល ។ លក្ខណៈវិនិច្ឆ័យអន្តរជាតិយកចិត្តទុកដាក់ជា សំខាន់ទៅលើទិដ្ឋភាពបច្ចេកទេសនៃសកម្មភាពកាត់បន្ថយកាបូនរបស់គំរោង និងមានបំណង ធានាថា អត្ថប្រយោជន៍ដែលគេរំពឹងទុកពាក់ពន្ធ័នឹងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ មានដោយពិត អាចវាស់វែងបាន និងជាការកាត់បន្ថយឧស្ម័នបន្ថែម ។

*លក្ខណៈវិនិច្ឆ័យជាតិ :* ប្រទេសម្ចាស់ផ្ទះមានបុព្វសិទ្ធិដើម្បីសំរេចថា តើគំរោង ជួយក្នុងការសំរេចការអភិវឌ្ឍន៍ដោយចិរភាពឬទេ ហើយហេតុដូច្នេះត្រូវបង្កើតលក្ខណៈ វិនិច្ឆ័យថ្នាក់ជាតិ និងលក្ខខណ្ឌផ្សេងៗ ដើម្បីធានាឱ្យមានការវាយតំលៃរលូន សមហេតុសម ផល និងតម្លាភាព ។ ធាតុសំខាន់ៗរួមមាន : ការអនុលោមតាមក្របខ័ណ្ឌច្បាប់ និង នយោបាយដែលមានស្រាប់, ភាពសមស្របជាមួយអាទិភាពក្នុងស្រុក, ការផ្តល់យោបល់ពី អ្នកពាក់ពន្ធ័ដែលចូលរួមដោយផ្ទាល់ ឬប្រយោលក្នុងគំរោង, វត្តមាននៃធនធានមនុស្សមាន សមត្ថភាព និងធនធានស្ថាប័នគ្រប់គ្រាន់, និងសក្តានុពលសំរាប់លើកកំពស់ស្ថាប័ន និងការ កសាងសមត្ថភាពជាតិ ។

នៅក្នុងការធ្វើសេចក្តីសំរេចជ្រើសរើសយកលក្ខណៈវិនិច្ឆ័យណាមួយ ក្នុងចំណោម លក្ខណៈវិនិច្ឆ័យទាំងនេះ ប្រទេសជាម្ចាស់ផ្ទះត្រូវពិចារណាអំពីទំនាក់ទំនងផ្ទាល់រវាងលក្ខខណ្ឌ និងការចំណាយប្រតិបត្តិ (transaction costs) ។ នៅពេលដែលមានលក្ខខណ្ឌកាន់តែច្រើន ដាក់ទៅលើអ្នកធ្វើគំរោង នោះការចំណាយប្រតិបត្តិក៏កាន់តែខ្ពស់ ។ នៅក្នុងទីផ្សារកាបូន មួយ ដែល CDM មានលក្ខខណ្ឌដើមច្រើនរួចជាស្រេចហើយនោះ ប្រទេសម្ចាស់ផ្ទះត្រូវថ្លឹង ថ្លែងពីតំរូវការពិតមានចាំបាច់សំរាប់ការត្រួតពិនិត្យគុណភាព ជាមួយនឹងកំណើននូវចំណាយ ប្រតិបត្តិ ។

ធាតុសំខាន់មួយទៀតសំរាប់ទាក់ទាញការវិនិយោគ CDM គឺការទទួលអនុវត្ត ដោយប្រទេសម្ចាស់ផ្ទះនូវនីតិវិធីដែលរហ័ស និងមានតំលាភាព សំរាប់ជ្រើសរើស វាយតំលៃ

និងអនុម័តគំរោង ។ ដើម្បីសំរេចទិសដៅនេះ អាជ្ញាធរជាតិ CDM ត្រូវអនុវត្តប្រព័ន្ធស្តង់ដា មួយ ដើម្បីជ្រើសរើស វាយតំលៃ និងអនុម័តគំរោង CDM ។ ប្រទេសម្ចាស់ផ្ទះចាំបាច់ត្រូវបង្កើតគោលការណ៍ណែនាំសំរាប់ការដាក់គំរោងជូន ។ ចំពោះការផ្តល់សុពលភាព និងការបញ្ជាក់គំរោង CDM ត្រូវតែព្រាងឡើងនៅក្នុងទំរង់ជាឯកសាររៀបចំគំរោង (Project Design Document: PDD) ។ គោលការណ៍ណែនាំសំរាប់ការដាក់គំរោងជូន ត្រូវតែមានភាពរលូន និងមានតំលាភាព ដែលជួយសំរួលដល់អ្នកធ្វើគំរោងមិនឱ្យប្រទះនឹងការផ្លាស់ប្តូរខ្នាត ។

## ការកំណត់ និងការរៀបចំគំរោង

ដើម្បីជំរុញការវិនិយោគ CDM ប្រទេសម្ចាស់ផ្ទះអាចរៀបចំវគ្គបណ្តុះបណ្តាលសំរាប់អ្នកធ្វើគំរោង ដែលនៅពេលនោះពួកគេត្រូវបានបង្ហាញពីរបៀបកំណត់គំរោងដែលមានសក្តានុពល អាចយល់ដឹងអំពីបរិបទនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងទីផ្សារការបូន ព្រមទាំងធ្វើឱ្យពួកគេយល់ដឹងអំពីឯកសាររៀបចំគំរោង ។ វគ្គបណ្តុះបណ្តាលអាចមានសារៈសំខាន់ផងដែរ ដើម្បីយល់ដឹងអំពីទិដ្ឋភាពស៊ីជំរៅបន្ថែមទៀតរបស់គំរោង CDM ដូចជាការរៀបចំឯកសារត្រឹមត្រូវសំរាប់ការបង្កើតមូលដ្ឋានគោល (baseline) (រួមមានការសន្មត និងវិធីសាស្រ្តដែលប្រើ), ព្រមទាំងការគណនាការបញ្ចេញឧស្ម័នពីគំរោង, ការកាត់បន្ថយ និងកាលេចចេញ (leakage) ពោលគឺជាឥទ្ធិពលដោយប្រយោលរបស់គំរោងកាត់បន្ថយការបញ្ចេញឧស្ម័ន ដែលនាំឱ្យមានកំនើនការបញ្ចេញឧស្ម័ននៅកន្លែងផ្សេងទៀត ។ សិក្ខាកាមនៅក្នុងវគ្គបណ្តុះបណ្តាលអាចជា អ្នកអភិវឌ្ឍន៍គំរោង ក្រុមហ៊ុនឯកជន ស្ថាប័នរដ្ឋាភិបាល ធនាគារិក អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងអ្នកពាក់ព័ន្ធផ្សេងៗទៀត ។ ប្រទេសម្ចាស់ផ្ទះអាចបង្កលក្ខណៈងាយស្រួលដល់ការវិនិយោគអន្តរជាតិ តាមរយៈការបង្កើតនូវបញ្ជីគំរោង CDM ផ្សេងៗ ដែលមានគុណភាពខ្ពស់ ដើម្បីឆ្លើយតបទៅនឹងតំរូវការ និងការចាប់អារម្មណ៍ នៃអ្នកវិនិយោគគ្រប់ប្រភេទ ។

# សេចក្តីបញ្ចប់

វិសាលភាពនៃអត្ថប្រយោជន៍ ដែលប្រទេសកំពុងអភិវឌ្ឍន៍អាចទទួលបានពី CDM ពិបាកនឹងទស្សន៍ទាយទុកជាមុនណាស់ ប៉ុន្តែសក្តានុពលធំធេងរបស់គំរោងដើម្បីជំរុញការអភិវឌ្ឍន៍ដោយចីរភាព និងបង្កើនលំហូរការវិនិយោគអន្តរជាតិមានភាពច្បាស់លាស់ពិតប្រាកដ ។ ជាមួយនឹងការធ្វើផែនការដែលមានការពិចារណាហ្មត់ចត់ និងការរៀបចំយុទ្ធសាស្ត្រជាតិ CDM គំរោង CDM អាចជួយដោះស្រាយបញ្ហាបរិស្ថាននៅក្នុងស្រុក និងក្នុងតំបន់ ហើយធ្វើឱ្យចំរើនដល់ទិសដៅអភិវឌ្ឍន៍សង្គម ។ CDM អនុញ្ញាតឱ្យប្រទេសកំពុងអភិវឌ្ឍន៍ចូលរួមជាមួយកិច្ចខិតខំប្រឹងប្រែងជាសកល ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងពេលវេលាមួយ ដែលអាទិភាពអភិវឌ្ឍន៍របស់រដ្ឋាភិបាលនៃប្រទេសនោះ អាចក៏រិតនូវថវិកាដែលអាចយកមកប្រើប្រាស់ សំរាប់សកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ។ គោលបំណងរបស់ CDM ស្តីពីការធ្វើឱ្យចំរើនដល់ទិសដៅអភិវឌ្ឍន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ ទទួលស្គាល់ថា មានតែតាមរយៈការអភិវឌ្ឍន៍ដោយចីរភាពទេ ដែលអាចឱ្យប្រទេសទាំងអស់ដើរតួក្នុងកិច្ចការពារអាកាសធាតុបាន ។

## ឧទាហរណ៍នៃគំរោងអភិវឌ្ឍន៍ស្អាត

សំរាប់ផ្នែកខាងក្រោមនេះ អក្សរកាត់ AIJ (Actions Implemented Jointly) នៅពីមុខឈ្មោះប្រទេសម្ចាស់ផ្ទះ មានន័យថា ជាឧទាហរណ៍ដែលទាញមកពីដំណាក់កាលសាកល្បងនៃសកម្មភាពអនុវត្តរួមគ្នា (Actions Implemented Jointly) ដែលជាអ្នកឈានមុខរបស់ CDM រៀបចំឡើងនៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ។

### ប្រសិទ្ធិភាពថាមពលនៅកន្លែងប្រើប្រាស់ (End-Use Energy Efficiency)

### វិធានការប្រសិទ្ធិភាពថាមពលក្នុងឡចំហាយឧស្សាហកម្ម (ប្រទេសវៀតណាម)

គំរោងនេះត្រូវបានរៀបចំតាមរយៈ យុទ្ធសាស្ត្រកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលចំណាយតិចនៅអាស៊ី (Asia Least-Cost Greenhouse Gas Abatement Strategy: ALGAS) ហើយនឹងលើកកំពស់ប្រសិទ្ធិភាពឡចំហាយនៅក្នុងវិស័យឧស្សាហកម្ម ។ ការកែលំអនេះនឹងមានតំលៃវិនិយោគទាប ហើយរួមមានឧបករណ៍វាស់ស្ទង់ដូចតទៅ : គ្រឿងឧបករណ៍វាស់ស្ទង់ គ្រឿងឧបករណ៍ត្រួតពិនិត្យ និងរូបធាតុអ៊ីសូឡង់ ។ គំរោងនឹងផ្សព្វផ្សាយបច្ចេកវិទ្យាថ្មីដល់រោងចក្រឧស្សាហកម្ម និងលើកឡើងនូវវិធានការពាក់ព័ន្ធផ្សេងទៀតសំរាប់ធ្វើឱ្យទំនើប ។

គោលបំណងសំខាន់របស់គំរោង គឺកាត់បន្ថយការប្រើប្រាស់ថាមពលរបស់ឡចំហាយឧស្សាហកម្មក្នុងមួយខ្នាតផលិតផល ហើយជាលទ្ធផល នាំឱ្យមានការកាត់បន្ថយការបញ្ចេញឧស្ម័ន $CO_2$ នៅក្នុងវិស័យឧស្សាហកម្ម ។ នៅប្រទេសវៀតណាម វិស័យឧស្សាហកម្ម គឺជាប្រភពបញ្ចេញឧស្ម័ន $CO_2$ ច្រើនជាងគេ ពោលគឺមានប្រមាណ 40% នៃការបញ្ចេញឧស្ម័នសរុប ។

ការបញ្ចេញឧស្ម័នគោលសំរាប់គំរោង គឺការបន្តប្រើប្រាស់ឡចំហាយគ្មានប្រសិទ្ធិភាព នៅប្រទេសវៀតណាមដែលមានទិន្នផលជាមធ្យម 45% ។ ការកែលំអដែលបានស្នើឡើង នឹងបង្កើនប្រសិទ្ធិភាពរបស់ឡចំហាយឧស្សាហកម្ម ជាមធ្យមដល់ 60% ។ គំរោងនឹងនាំមកនូវការកាត់បន្ថយការបញ្ចេញឧស្ម័ន ដែលបានប៉ាន់ស្មានថាមានចំនួន 150 គីឡូតោន ក្នុងមួយឆ្នាំ ។ គំរោងនេះក៏ជួយកាត់បន្ថយការបញ្ចេញសារធាតុបំពុលខ្យល់ក្នុងស្រុកផងដែរ ។ គំរោងនេះមានសារៈសំខាន់នៅក្នុងប្រទេសវៀតណាម ពីព្រោះវិស័យឧស្សាហកម្មចូលរួមចំណែកដល់ការបញ្ចេញឧស្ម័ន $S_2O$ ខ្ពស់ជាងគេបំផុត ហើយជាវិស័យដែលបញ្ចេញឧស្ម័ន $NO_x$ ខ្ពស់ជាងគេបំផុតទីពីរផងដែរ ។

**ប្រសិទ្ធិភាពថាមពលនៅកន្លែងផ្គត់ផ្គង់ (Supply-Side Energy Efficiency)**

**គំរោងថាមពល និងកំដៅ នៅរោងចក្រផលិតថាមពលដើរដោយកំដៅ សៀងគី ខេត្តហេណាន ប្រទេសចិន** (Combined Heat and Power (CHP) Project in Shangqiu Thermal Power Plant in Henan Province (AIJ-China))

សំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន គំរោងថាមពល និងកំដៅអាចផ្តល់នូវមូលដ្ឋានសំខាន់សំរាប់ CDM ដែលមានសក្តានុពល ។ គំរោងនេះមានទិសដៅដើម្បីជំនួសឡចំហាយឧស្សាហកម្មដុតធ្យូងថ្មតូចៗ មានប្រសិទ្ធិភាពទាបចំនួន 24 ដែលផ្គត់ផ្គង់កំដៅដល់ដំណើរការឧស្សាហកម្មកំដៅ ដោយឡចំហាយដុតធ្យូងថ្មប្រភេទថ្មី ឈ្មោះ coal-fired circulating fluidised bed combustion boilers (CFBC) រួមជាមួយជនិតាអគ្គិសនីដែលមានកំលាំង 24 មេហ្គាវ៉ាត់ ។ រោងចក្រនឹងផ្គត់ផ្គង់ថាមពលដល់រោងចក្រសួអាលុយ-មីញ៉ូម សៀងគី ហើយគំរោងនឹងអាចឱ្យរោងចក្រនេះបំពេញតំរូវការអតិបរមា (load demand) របស់វា សំរាប់សមត្ថភាពសួអាលុយមីញ៉ូមកើនដល់ 15.000 តោន ក្នុងមួយឆ្នាំ ដោយមិនបារម្ភពីការដាច់ភ្លើង ឬខ្វះភ្លើងឡើយ ។

គំរោងនឹងសន្សំសំចៃធ្យូងថ្មបាន 965 TJ ក្នុងមួយឆ្នាំ ដែលនាំឱ្យមានការកាត់បន្ថយការបញ្ចេញឧស្ម័នបាន 88 គីឡូតោន ក្នុងមួយឆ្នាំ ។ ការបំពុលនៅក្នុងមូលដ្ឋាន និង

តំបន់ នឹងត្រូវបានកាត់បន្ថយ ដោយសារការបញ្ចេញឧស្ម័ន $S_2O$ នឹងត្រូវកាត់បន្ថយយ៉ាងមានប្រសិទ្ធិភាព តាមរយៈការដកស្ពាន់ធ័រចេញដល់ ៨៥% នៅក្នុងឡ CFBC ។ ភាគល្អិត និងធូលីនឹងត្រូវកាត់បន្ថយ ៩៥% ហើយឧស្ម័នអាសូតអុកស៊ីតនឹងត្រូវថយចុះដែរ ។

## ថាមពលសំណល់

### គំរោងផលិតថាមពលពីប្រភពជីវៈម៉ាស ដំណាក់កាលទីមួយ (AIJ ហុងឌុយរាស់)

**((Bio-Gen Biomass Power Generation Project, Phase I (AIJ-Honduras))**

ថាមពល និងកំដៅអាចត្រូវបានបង្កើតឡើងពីសំណល់កសិកម្ម ដូចជាសំបកសណ្តែកដី អង្កាម សំបកផ្លែដូង សំណល់ដែលបានមកពីការចំរាញ់ទឹកផ្លែក្រូច សំណល់ផលិតកម្មដូងប្រេង សំណល់ពីការកាប់ឈើ សំណល់ឈើពីរោងចក្រអារឈើ ។ល។ ក្នុងករណីជាច្រើន គំរោង CDM របៀបនេះនឹងកាត់បន្ថយទាំងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ទាំងបញ្ហាការបំពុលបរិស្ថាននៅនឹងកន្លែង ។

ឧទាហរណ៍មួយ គឺគំរោងផលិតថាមអគ្គិសនី 15 មេហ្កាវ៉ាត់ ពីសំណល់ជីវៈម៉ាស នៅ ហ្គាយម៉ាកា (Guaimaca) ប្រទេស ហុងឌុយរ៉ាស ។ រោងចក្រនេះនឹងប្រើប្រាស់សំណល់ឈើ ដែលបានមកពីដំណើការកែច្នៃផលិតផលព្រៃឈើនៅក្នុងតំបន់ ។ សំណល់រួមមាន សំណល់ពីការកាប់ឈើ និងសំណល់ឈើពីរោងចក្រអារឈើ ដែលបច្ចុប្បន្ននេះត្រូវគេដុតចោល ដោយពុំមានការត្រួតពិនិត្យ ឬចាក់ចោលទៅក្នុងទន្លេ ឬទៅក្នុងតំបន់ជ្រៅៗ ។ គំរោងនឹងកាត់បន្ថយការបញ្ចេញឧស្ម័នបាន 119 ពាន់តោន ដែលចេញមកពីការប្រើប្រាស់ប្រេងដុតនៅក្រោមលក្ខខណ្ឌគោល (baseline) ។ ថាមពលដែលផលិតដោយរោងចក្រនឹងត្រូវលក់ឱ្យអ្នកចែកចាយជាតិ ហើយនឹងជំនួសថាមពលអគ្គិសនី ដែលផលិតចេញពីឥន្ទនៈផូស៊ីល ដោយកាត់ការបញ្ចេញឧស្ម័នទាំងស្រុង ។

រោងចក្រនឹងអាចដំណើរការ សំរាប់ឆ្លើយតបទៅនឹងតំរូវការអគ្គិសនីជាមូលដ្ឋាន ហើយនឹងដំណើរការ 7.500 ម៉ោងក្នុងមួយឆ្នាំ ។ ដូច្នេះ ដោយសារតំរូវការថាមពលអគ្គិសនីត្រូវគេរំពឹងថា នឹងកើនឡើងក្នុងកំរិតខ្ពស់នៅប្រទេសហុងឌុយរាស នោះបរិមាណ

ថាមពលបានមកពីគំរោងនេះ នឹងកាត់បន្ថយបរិមាណឥន្ធនៈផូស៊ីល ដែលត្រូវប្រើប្រាស់ ក្នុងករណីពុំមានរោងចក្រ ។ សមត្ថភាពថ្មីរបស់គំរោងអាចជួយកាត់បន្ថយផងដែរនូវការកាត់ចរន្តអគ្គិសនីជាអន្លើៗ ដែលបច្ចុប្បន្នធ្វើឱ្យរំខានដល់រោងចក្រអារឈើមួយចំនួន មិនឱ្យដំណើរការដោយប្រសិទ្ធិភាព ។ គំរោងនេះក៏អាចដើរតួជាឧទាហរណ៍សំរាប់ជំរុញបណ្តាគំរោងផ្សេងៗនៅរោងចក្រអារឈើ ឬនៅក្នុងវិស័យឧស្សាហកម្មផ្សេងៗទៀត ដោយធ្វើឱ្យរោងចក្រនៅក្នុងស្រុកច្រើនថែមទៀត អាចផ្គត់ផ្គង់ថាមពលរបស់គេគ្រប់គ្រាន់ដោយខ្លួនឯង ។

## ថាមពលខ្យល់

**អគ្គិសនីកម្មនៅតំបន់ជនបទ អាលីសេ (AIJ-ម៉ូរីតានី) ((Alizés Rural Electrification (AIJ-Mauritania))**

គំរោងនេះមានគោលដៅតំលើងតួប៊ីនខ្យល់តូចៗមានកំលាំង 1 គីឡូវ៉ាត់ នៅក្នុងភូមិចំនួន 150 តាមតំបន់ជនបទ ដែលគ្មានថាមពលអគ្គិសនី ។ តួប៊ីនខ្យល់នឹងផ្គត់ផ្គង់ថាមពលទៅស្ថានីយសាកអាគុយ ដែលគ្រួសារជាច្រើននឹងប្រើជាប្រភពអគ្គិសនីរបស់គេ ។ អគ្គិសនីដែលបានមកពីតួប៊ីនខ្យល់នឹងជំនួសប្រេងកាត ទៀន និងអាគុយ សំរាប់គ្រួសារមួយចំនួនធំ ។ គ្រួសារណាប្រើអាគុយរួចហើយ នឹងសន្សំពេលវេលាដឹកជញ្ជូនឆ្ងាយ ដើម្បីយកអាគុយរបស់ពួកគាត់ទៅកាន់កន្លែងបញ្ចូលភ្លើង ហើយឧស្ម័ន $CO_2$ នឹងមិនត្រូវបានបញ្ចេញនៅពេលដែលបញ្ចូលភ្លើងអាគុយរបស់ពួកគាត់ទេ ។ ការកាត់បន្ថយការបញ្ចេញឧស្ម័ន $CO_2$ សរុបប្រចាំឆ្នាំពីគ្រួសារចំនួន 7.500 នៅក្នុងភូមិចំនួន 150 ត្រូវបានគណនាមានប្រមាណ 0,88 ពាន់តោន ។

នៅម៉ូរីតានី មានតែទីក្រុងសំខាន់ៗប៉ុណ្ណោះទេដែលមានការផ្គត់ផ្គង់អគ្គិសនី ។ ចំនួនអ្នកក្រីក្រនៅទីក្រុងកំពុងកើនឡើងយ៉ាងឆាប់រហ័ស ដោយសារតែចំណាកស្រុកពីជនបទ ។ និន្នាការនេះប្រហែលជានៅតែបន្ត ដោយសារអវត្តមាននៃសេវាកម្មសង្គមជាមូលដ្ឋាននៅជនបទ ។ ដើម្បីកែលំអគុណភាពនៃជីវភាពរស់នៅ ក្នុងតំបន់ជនបទ និងទប់ស្កាត់ការហូរចូលនៃអ្នកចំណាកស្រុក មកកាន់តំបន់អនាធិបតេយ្យនៅទីក្រុង ចាំបាច់ត្រូវ

រៀបចំការផ្គត់ផ្គង់ថាមពល និងអគ្គិសនីប្រកបដោយគុណភាពខ្ពស់ ដែលជាគ្រឹះនៃការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច ។

ម៉ូរីតានីគឺជាប្រទេសមួយ ដែលមានខ្យល់បក់ខ្លាំងជាងគេ ក្នុងចំណោមប្រទេសនៅអាហ្វ្រិចខាងលិច ហើយគំរោងនេះបង្កើតឡើងដោយផ្អែកលើបទពិសោធន៍ដ៏ជោគជ័យរបស់កម្មវិធី អាលីសេ ដែលជាគំនិតផ្តួចផ្តើមរួមគ្នារបស់អង្គការមិនមែនរដ្ឋាភិបាលរបស់បារាំងឈ្មោះ GRET (ក្រុមស្រាវជ្រាវ និងផ្លាស់ប្តូរបច្ចេកវិទ្យា (Technological Research and Exchange Group)) និងក្រសួងថាមពលរបស់ម៉ូរីតានី ។ កម្មវិធីអាលីសេ បានផ្ទេរបច្ចេកវិទ្យាបូមទឹកមេកានិចដើរដោយកំលាំងខ្យល់ ដល់ភូមិជាច្រើននៅប្រទេសម៉ូរីតានី និងសេនេហ្គាល ។ គំរោង CDM បែបថ្មីដែលផលិតថាមពលអគ្គិសនីពីខ្យល់នឹងកសាងសមត្ថភាពវិស័យឯកជន បង្កើតបណ្តាញឥណទាន និងជួយបង្កលក្ខណៈងាយស្រួលដល់កិច្ចសហការជាមួយក្រុមហ៊ុនផ្គត់ផ្គង់សំភារៈ និងសេវាកម្មបរទេស ។ ដំណាក់កាលទីមួយនៃការតំលើងតួប៊ីនខ្យល់តូចៗចំនួន 40 ត្រូវបានបញ្ចប់ក្រោមហិរញ្ញប្បទានរបស់មូលនិធិបរិស្ថានពិភពលោក (GEF) ។

## ថាមពលព្រះអាទិត្យ

### ថាមពលព្រះអាទិត្យសំរាប់កំដៅទឹកតាមគេហដ្ឋាន នៅអាហ្វ្រិចខាងត្បូង

**(Residential Solar Water Heating, South Africa)**

អាហ្វ្រិចខាងត្បូងគឺជាប្រទេសស្ងួត ដែលមានរបបកំដៅព្រះអាទិត្យល្អបំផុត ក្នុងចំណោមបណ្តាប្រទេសទាំងឡាយ ពោលគឺមានថាមពលរស្មីព្រះអាទិត្យប្រមាណ 2.190 គីឡូវ៉ាត់ម៉ោង/ម$^{២}$/ឆ្នាំ ។ គំរោងដែលបានស្នើឡើងស្តីពីថាមពលព្រះអាទិត្យសំរាប់កំដៅទឹក (Solar Water Heating: SWH) គឺស្ថិតនៅក្នុងគំរោងអភិវឌ្ឍន៍សណ្ឋាគារ នៅល្វានដល (Lwandle) ជាតំបន់ដែលមានចំណូលតិចនៅក្នុងទីក្រុងកេបថោន ។ សហគមន៍បានពេញចិត្តជ្រើសរើស SWH ដែលមានជំនួយបំរុង (back up) (ពីអគ្គិសនី ឬឧស្ម័ន) ជាបច្ចេកវិទ្យាសំរាប់កំដៅទឹក ដែលបានកែលំអជាច្រើនឆ្នាំកន្លងមក ប៉ុន្តែមូលនិធិមានកំណត់

និងអវត្តមាននៃការលើកទឹកចិត្តដោយផ្ទាល់ បានធ្វើឱ្យគំរោងមិនត្រូវបានអនុវត្ត ។ គំរោងនេះត្រូវបានរៀបចំឡើងដោយមជ្ឈមណ្ឌលស្រាវជ្រាវថាមពល និងអភិវឌ្ឍន៍ នៃសាកលវិទ្យាល័យកេបថោន ។

ឧទាហរណ៍នេះបង្ហាញថា សក្តានុពលនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់គំរោងថាមពលព្រះអាទិត្យសំរាប់កំដៅទឹក អាស្រ័យយ៉ាងខ្លាំងទៅលើលក្ខខណ្ឌគោល (baseline) ។ លំនៅដ្ឋាននៅទីក្រុង Lwandle បច្ចុប្បន្នកំពុងប្រើប្រាស់ចង្ក្រានប្រេងកាតសំរាប់កំដៅទឹក ។ ប៉ុន្តែ ដោយមានការជំរុញទៅរកអគ្គិសនីកម្ម និងបំណងធ្វើឱ្យទាន់សម័យនូវសណ្ឋាគារ និងលំនៅដ្ឋាន អ្នករស់នៅទីនោះប្រហែលជានឹងទទួលបាននូវឆ្នាំងកំដៅទឹកអគ្គិសនីស្តង់ដា ក្នុងអនាគតឆាប់ៗនេះ ។ ប្រសិនបើគេហដ្ឋានចំនួន 341 នៅក្នុងគំរោងត្រូវបានផ្គត់ផ្គង់ដោយ SWH ដែលមានជំនួយបំរុងពីអគ្គិសនី នោះការបញ្ចេញឧស្ម័នត្រូវបានកាត់បន្ថយ 4,7 ពាន់តោន $CO_2$ ក្នុងមួយឆ្នាំ នៅពេលដែលលក្ខខណ្ឌគោលគឺជាឆ្នាំងកំដៅទឹកអគ្គិសនី ។ ក៏ប៉ុន្តែ ប្រសិនបើគេសន្មតយកឆ្នាំងកំដៅទឹកប្រេងកាតជាលក្ខខណ្ឌគោលវិញ នោះការបញ្ចេញឧស្ម័ននឹងកើនថែម 0,7 ពាន់តោន $CO_2$ ទៀតក្នុងមួយឆ្នាំ ។ ដោយសារអគ្គិសនីត្រូវបានផលិតពីធ្យូងថ្ម ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីជំនួយបំរុងអគ្គិសនីមានច្រើនជាងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីឆ្នាំងកំដៅទឹកប្រើប្រេងកាត ។ ក្នុងករណីចុងក្រោយនេះ គំរោងនឹងកាត់បន្ថយតែការបំពុលខ្យល់ក្នុងតំបន់ពីចំហេះប្រេងកាតប៉ុណ្ណោះ ។

គេរំពឹងថា គំរោងនឹងបង្កើតការងារ និងកំនើនលូតលាស់សេដ្ឋកិច្ចក្នុងតំបន់ តាមរយៈសហគ្រិនខ្នាតតូច ដែលជាអ្នកទទួលបន្ទុកតំលើង និងថែទាំ SWH លក់ទឹកក្តៅ និងផលិតផលបន្ទាប់បន្សំ ដូចជាការប្រើទឹកក្តៅក្នុងហាងអ៊ុតសក់ និងកន្លែងបោកគក់ ជាដើម ។

**ថាមពលទំរង់អគ្គិសនី (Hydro)**

**គំរោងវារីអគ្គិសនីដើរដោយចរន្តទឹកទន្លេកំលាំង 26 មេហ្គាវ៉ាត់នៅ ឆាកាប៊ុគិតូ ប្រទេសស៊ីលី (Chacabuquito 26 MW Run off River Hydropower Project, Chile)**

នៅចំងាយប្រមាណ 100 គីឡូម៉ែត ភាគខាងជើងទីក្រុងសង់តាហ្គោ ប្រទេសស៊ីលី មានរោងចក្រវារីអគ្គិសនីមួយនឹងត្រូវសាងសង់ឡើង ហើយតភ្ជាប់ទៅបណ្តាញកណ្តាលក្នុងប្រទេសស៊ីលី ដោយជំនួសការផលិតអគ្គិសនីដោយប្រើធ្យូងថ្ម ។ គំរោងដែលកំពុងអភិវឌ្ឍក្រោមមូលនិធិកាបូនគំរូរបស់ធនាគារពិភពលោក (World Bank's Prototype Carbon Fund: PFC) ដើម្បីបង្កើត CER សំរាប់អំឡុងពេល 7 ឆ្នាំ និងអាចបន្ត 3 ដង អាស្រ័យលើការអភិវឌ្ឍន៍លក្ខខណ្ឌគោល ។ ការកាត់បន្ថយឧស្ម័ន $CO_2$ សរុបក្នុងអំឡុងពេល 21 ឆ្នាំ មាន 2,8 លានតោន ។ តំលៃប៉ាន់ស្មានសរុបមាន 37 លានដុល្លារ ហើយអាចផលិតថាមពលសរុបបាន 175 ហ្គីហ្គាវ៉ាត់ម៉ោង (ថាមពលសុទ្ធប្រចាំឆ្នាំចំនួន 160 ហ្គីហ្គាវ៉ាត់ម៉ោង) ។

គំរោងនេះនឹងជួយរួមចំណែកដល់ការអភិវឌ្ឍន៍ដោយចីរភាពនៅប្រទេសស៊ីលីតាមរយៈ :

- ការប្រើប្រាស់ធនធានថាមពលកើតឡើងវិញក្នុងស្រុក (ថាមពលវារីអគ្គិសនីខ្នាតតូចដើម្បីជំនួសថាមពលកំដៅ ដើរដោយធ្យូងថ្ម)
- បានបង្កើនសកម្មភាពពាណិជ្ជកម្មតាមរយៈប្រភពថាមពលស្អាត និងកើតឡើងវិញ
- បង្កើតការងារក្នុងតំបន់ដែលគំរោងតាំងនៅ ។

របាយការណ៍ស្តីពីផលប៉ះពាល់បរិស្ថានរបស់គំរោងបានបង្ហាញថា ពុំមានផលប៉ះពាល់ជាសំខាន់ផ្នែកអេកូឡូស៊ី ឬសង្គម នៅតំបន់ទីជំរាលទេ ។ គំរោងនេះត្រូវបានឯកភាពយល់ព្រមដោយគណៈកម្មការបរិស្ថានជាតិ ដែលធ្វើជាប្រធានគណៈកម្មាធិការផ្តល់យោបល់ជាតិស្តីពីការប្រែប្រួលអាកាសធាតុពិភពលោក ។

## ថាមពលជីវៈម៉ាស (Biomass)

### ផលិតកម្មអុស និងធ្យូងប្រកបដោយនិរន្តរភាពសំរាប់ឧស្សាហកម្មស្លដែក នៅ Minas Gerais, គំរោង Planter (ប្រទេសប្រេស៊ីល)

នៅក្នុងគំរោងរបស់មូលនិធិកាបូនគំរូនេះ ឥន្ធនៈផូស៊ីលនឹងត្រូវជំនួសដោយថាមពលជីវៈម៉ាសដែលមាននិរន្តរភាព ។ ភោគទ្រព្យរ៉ែសំខាន់ៗ អុស និងសក្តានុពលវ៉ារីអគ្គិសនី បានជំរុញប្រទេសនេះល្បីឈ្មោះជាមជ្ឈមណ្ឌលដែកស្មិត និងដែកថែបប្រេស៊ីលនៅទសវត្សឆ្នាំទី ១៩៦០ និង ១៩៧០ ។ ឧស្សាហកម្មទាំងនេះ ជាដំបូងបានពឹងផ្អែកទាំងស្រុងលើការផ្គត់ផ្គង់ធ្យូងពីព្រៃធម្មជាតិ ។ បច្ចុប្បន្ន វិស័យផលិតកម្មស្លដែកមានពីរផ្នែក : រោងចក្រស្លដែកខ្នាតធំដែលប្រើធ្យូងកូក និងក្រុមហ៊ុនឯករាជ្យតូចៗ ដែលមានភាគចំណែកផលិតកម្មចំនួន 25% នៃផលិតកម្មសរុប ។

គំរោងនេះទាក់ទងជាមួយអ្នកផលិតដែលប្រើប្រាស់ធ្យូង ដោយមានចង្ក្រានសប់ខ្យល់ធុនតូចប្រើធ្យូងប្រហែល ៩០.០០០ តោនក្នុងមួយឆ្នាំ ។ ភាគច្រើននៃរោងចក្រទាំងនោះត្រូវបិទទ្វារ ពីព្រោះគេមិនអាចប្រើធ្យូងពីព្រៃធម្មជាតិ (ដោយសារការរឹតបន្តឹងផ្នែកផ្លូវច្បាប់) ហើយពួកគេមិនមានធនធានដើម្បីប្តូរទៅប្រើធ្យូងពីចំការព្រៃឈើគ្រប់គ្រង ។ រោងចក្រខ្លះបានផ្លាស់ទីតាំងទៅកន្លែងផ្សេងទៀត ដែលពុំសូវមានការរឹតបន្តឹងចំពោះការប្រើប្រាស់ព្រៃឈើសំរាប់ផលិតកម្មធ្យូង ។ នៅឆ្នាំ 1992 មានក្រុមហ៊ុនចំនួន 67 នៅ Manas តែសព្វថ្ងៃនេះនៅសល់តែ 37 ក្រុមហ៊ុនប៉ុណ្ណោះ ។ ដូច្នេះ គំរោងនេះមានផលប៉ះពាល់ជាវិជ្ជមានយ៉ាងសំខាន់ទៅលើសេដ្ឋកិច្ចជនបទនៃរដ្ឋ Manas Geras ។ គំរោងនេះមានទិសដៅបង្កើតចំការព្រៃ eucalyptus ដែលមានទិន្នផលខ្ពស់ លើផ្ទៃដីទំហំ 23.100 ហិចតា ក្នុងរវាងឆ្នាំ 2002 និង 2009 ដើម្បីផ្គត់ផ្គង់ឈើសំរាប់ផលិតកម្មធ្យូង ។ ធ្យូងនឹងត្រូវផលិតដោយអនុវត្តតាមបច្ចេកវិទ្យាកាបូនកម្ម ដែលបច្ចុប្បន្ននេះមានប្រើនៅប្រទេសប្រេស៊ីល ។ បច្ចេកវិទ្យានេះនឹងកាត់បន្ថយការបញ្ចេញមេតានបាន 70% ពីដំណើរការផលិតធ្យូង ហើយអាចឱ្យគេទាញយកបាននូវប្រេងពីរ៉ូលីទិច (pyrolytic oils) និងជ័រ ដែលមានតំលៃពាណិជ្ជកម្ម ។ ការកាត់បន្ថយការបំពុលនៅនឹងកន្លែងនេះនឹងធ្វើឱ្យប្រសើរដល់សុខភាព

កម្មករផលិតធ្យូង ។ ក្នុងរយៈពេលរហូតដល់ឆ្នាំ 2010 នៅពេលដែលចំការ eucalyptus លូតលាស់ពេញវ័យ ឧស្ម័នការបូនិចប្រមាណ 5 លានតោនត្រូវបានចាប់យកពីបរិយាកាស ។ នៅពេលដែលផលិតកម្មធ្យូងត្រូវបង្កើតឡើង ការដាំឈើក៏ចាប់ផ្តើម ។ បន្ទាប់ពីនោះមក ការកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិចប្រចាំឆ្នាំ ដោយសារការប្រើប្រាស់ធ្យូងថ្មមានកំរិតទាប មានប្រហែល 4 លានតោន នៃឧស្ម័នកាបូនិច ។

# សន្ទានុក្រម

| | |
|---|---|
| Assigned Amount Unit | ឯកតាបរិមាណដែលបានកំណត់ |
| Baseline | គោល, លក្ខខណ្ឌគោល |
| Baseline emission | ការបញ្ចេញឧស្ម័នគោល |
| Certified emission reduction (CER) | ការកាត់បន្ថយឧស្ម័នដែលបានបញ្ជាក់ |
| Clean Development Mechanism | យន្តការអភិវឌ្ឍន៍ស្អាត |
| Climate change | ការប្រែប្រួលអាកាសធាតុ |
| Climate system | ប្រព័ន្ធអាកាសធាតុ |
| Common but differentiated responsibilities | ការទទួលខុសត្រូវរួមគ្នា តែមានកំរិតផ្សេងៗគ្នា |
| Conference of the Parties (CoP) | សន្និសីទបណ្តាភាគី |
| Crediting period | អំឡុងពេលឥណទាន |
| Eligibility | ភាពអាចជ្រើសរើសយកបាន, ភាពមានសិទ្ធិទទួល |
| Emission | ការបញ្ចេញឧស្ម័ន |
| Emission reduction unit | ឯកតាកាត់បន្ថយអេមីស្យុង |
| Greenhouse effect | ផលផ្ទះកញ្ចក់ |
| Greenhouse gas (GHG) | ឧស្ម័នផ្ទះកញ្ចក់ |
| Intergovernmental Panel on Climate Change (IPCC) | ក្រុមការងារអន្តររដ្ឋាភិបាល ស្តីពីការប្រែប្រួលអាកាសធាតុ |
| Join implementation | ការអនុវត្តន៍រួមគ្នា |
| Legally binding commitment | ការសន្យាជាលក្ខណៈច្បាប់ |
| National communication | របាយការណ៍ជាតិ |
| Operational entity | អង្គភាពប្រតិបត្តិ |
| Quantified emission limitation and reduction commitments | ការសន្យាកំហិត និងកាត់បន្ថយបរិមាណការបញ្ចេញឧស្ម័ន |
| Reservoir | អាងផ្ទុកកាបូន |
| Sink | អាងស្រូបកាបូន |
| Uncertainty | ភាពមិនប្រាកដប្រជា |
| United Nations Environment Programme (UNEP) | កម្មវិធីបរិស្ថានសហប្រជាជាតិ |
| Validation | ការផ្តល់សុពលភាព |
| World Meteorological Organisation | អង្គការឧតុនិយមពិភពលោក |

## សេចក្តីផ្តើមស្តីពីយន្តការអភិវឌ្ឍន៍ស្អាត (CDM)

ឯកសារនេះសង្ខេបអំពីតំលៃ និងអត្ថប្រយោជន៍សំរាប់ជាតិ ពីការចូលរួមនៅក្នុង CDM ហើយមានអធិប្បាយអំពីដំណើរការកំណត់ រៀបចំ ផ្តល់ហិរញ្ញប្បទាន និងអនុវត្តបណ្តាគំរោង CDM ព្រមទាំងអំពីការត្រួតពិនិត្យ ធ្វើរបាយការណ៍ ផ្ទៀងផ្ទាត់ និងបញ្ជាក់លទ្ធផល នៃការកាត់បន្ថយឧស្ម័នរបស់គំរោង CDM ។

សេចក្តីផ្តើមនេះមានពាក់ព័ន្ធទៅនឹងគំរោងធំមួយ របស់កម្មវិធីបរិស្ថានពិភពលោក ស្តីពី " ការកសាងសមត្ថភាពសំរាប់ CDM " ដែលអនុវត្តដោយមជ្ឈមណ្ឌលសហប្រតិបត្តិការ ផ្នែកថាមពល និងបរិស្ថាន របស់កម្មវិធីបរិស្ថានសហប្រជាជាតិ និងការិយាល័យពិសោធន៍ជាតិ Risø នៃប្រទេសដាណឺម៉ាក ។ ទិសដៅរួមរបស់គំរោង គឺការកសាងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស សំរាប់ការអនុវត្តន៍គំរោង CDM នៅប្រទេសកំពុងអភិវឌ្ឍន៍ ។

គំរោងនេះផ្តល់មូនិធិដោយ
ក្រសួងការបរទេសហុល្លង់

RISØ

Risø National Laboratory
Roskilde
Denmark